លេខ ៥ - ខែ ឧសភា ឆ្នាំ ១៩៨៧

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រឹត្យ-ច្បាប់
- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ
- សារាចរណែនាំ

ផ្សាយចេញពីខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រីជារៀងរាល់ខែ

មាតិកា

ទំព័រ

I– ក្រុមប្រឹក្សារដ្ឋមន្ត្រី

១_ អនុក្រឹត្យ

៣០-០៥-៨៧ អនុក្រឹត្យលេខ ១៥ អ.ន.ក្រ ស្ដីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ១៨២

៣០-០៥-៨៧ អនុក្រឹត្យលេខ ១៦ អ.ន.ក្រ ស្ដីពីការចាត់តាំងគណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាជននៅមូលដ្ឋាន ១៨៦

៣០-០៥-៨៧ អនុក្រឹត្យលេខ ១៧ អ.ន.ក្រ ស្ដីពីការចាត់តាំង និង សកម្មភាពរបស់ទីស្ដីការរដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យ ១៨៩

២_ សេចក្ដីសំរេច

០៦-០៥-៨៧ សេចក្ដីសំរេចលេខ ៦០ ស.ស.រ ស្ដីពីការប្រឡងសញ្ញាបត្រមធ្យមសិក្សាកំរិត ១ និង ការជ្រើសរើសចូលរៀនថ្នាក់ទី ៩ នៃមធ្យមសិក្សាកំរិតទី ២ ១៩២

២១-០៥-៨៧ សេចក្ដីសំរេចលេខ ៦៤ ស.ស.រ ស្ដីពីការបណ្ដុះបណ្ដាលអ្នកគ្រូមត្តេយ្យ " ៧ មករា " ១៩៦

២៦-០៥-៨៧ សេចក្ដីសំរេចលេខ ៦៨ ស.ស.រ ស្ដីពីថ្លៃលក់ចបកាប់ផលិតដោយក្រសួងឧស្សាហកម្ម ១៩៨

២៦-០៥-៨៧ សេចក្ដីសំរេចលេខ ៦៩ ស.ស.រ ស្ដីពីថ្លៃលក់ស៊ីម៉ង់ត៍ ១៩៩

២៦-០៥-៨៧ សេចក្ដីសំរេចលេខ ៧០ ស.ស.រ ស្ដីពីថ្លៃលក់បារីគ្រប់ប្រភេទ ២០០

៣– សារាចរ

២៩-០៥-៨៧ សារាចរលេខ ០៣ ស.រ ស្ដីពីការគ្រប់គ្រងសាច់ប្រាក់ចំពោះកងកម្លាំងប្រដាប់អាវុធ ។ ២០៣

៤ - សេចក្តីណែនាំ

១៦-០៥-៥៧ សេចក្តីណែនាំលេខ ០១ ស.ណ.ន ស្តីពីការអនុវត្តដំណើរការបោះឆ្នោតបំពេញបន្ថែមសមាជិករដ្ឋសភា ។ ២០៦

II- ការងារបណ្តាក្រសួង

១ _ ក្រសួងអប់រំ

ប្រកាស

១៤-០៥-៥៧ ប្រកាសលេខ ០១ អ.រ.ប្រ.ក ស្តីពីការកែប្រែ និង បន្ថែមប្រកាសលេខ ០១ អរ.ចកប្រ ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៨៥ ។ ២១០

សារាចរណែនាំ

២១-០៥-៥៧ សារាចរណែនាំលេខ ០១ អរ-ចទម ស្តីពីការជ្រើសរើសសិស្សអោយចូលរៀនថ្នាក់ទី ៦ នៃសាលារៀនបឋមសិក្សាកំរិត ១ ចំណេះទូទៅ ។ ២១៤

២ -ក្រសួងហិរញ្ញវត្ថុ

សេចក្តីសំរេច

១៥-០៥-៥៧ សេចក្តីសំរេចលេខ ០៤៧ ស.ស.រ-ក.ហ.វ ស្តីពីការកំណត់ចំណូលរដ្ឋរបស់សហគ្រាសយន្តសាស្ត្រក្រោមឱវាទក្រសួងឧស្សាហកម្ម ។ ២២២

I – ក្រុមប្រឹក្សារដ្ឋមន្ត្រី

១_ អនុក្រឹត្យ

អនុក្រឹត្យ លេខ ១៥ អ.ន.ក្រ

ស្តីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យ គ្រប់ថ្នាក់

ក្រុមប្រឹក្សារដ្ឋមន្ត្រី

— បានឃើញរដ្ឋធម្មនុញ្ញ នៃ សាធារណរដ្ឋប្រជាមានិតកម្ពុជា

– បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យ លេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២ ។

– បានឃើញក្រឹត្យ-ច្បាប់ លេខ ៣១ ក្រ.ច ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៨៧ ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យ ។

– បានឃើញក្រឹត្យ-ច្បាប់ លេខ ០៧ ក្រ.ច ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៨២ ស្តីពីសមត្ថកិច្ច និងនីតិវិធីនៃការធ្វើច្បាប់ និងបទបញ្ជា ។

– បានឃើញអនុក្រឹត្យ លេខ ៧៣ អនក្រ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៨៣ ស្តីពីការចាត់តាំងបណ្តាញត្រួតពិនិត្យតាមក្រសួង ខេត្ត-ក្រុង ជុំវិញមជ្ឈិម ។

– តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងត្រួតពិនិត្យ ។

សំរេច

មាត្រា ១.— បង្កើតគណៈកម្មាធិការត្រួតពិនិត្យនៅតាមទីស្តីការរដ្ឋមន្ត្រី រួចទាំងទីស្តីការរដ្ឋមន្ត្រីក្រសួងការពារប្រទេស និង ក្រសួងមហាផ្ទៃ ស្ថាប័នថ្នាក់ប្រហាក់ប្រហែលទីស្តីការរដ្ឋមន្ត្រី ខេត្ត-ក្រុង ចំណុះមជ្ឈិម ទីរួមខេត្ត ខណ្ឌ ស្រុក ស្រុកជាយក្រុងរួចមាន:

— គណៈកម្មាធិការត្រួតពិនិត្យទីស្តីការរដ្ឋមន្ត្រី និងស្ថាប័នថ្នាក់ប្រហាក់ប្រហែលនៅមជ្ឈិម

ស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់រដ្ឋមន្ត្រី និង ប្រធានស្ថាប័នថ្នាក់ប្រហាក់ប្រហែលនោះ និងស្ថិតក្រោមការណែនាំមុខជំនាញពីក្រសួងត្រួតពិនិត្យ ។

— គណៈកម្មាធិការត្រួតពិនិត្យខេត្ត - ក្រុង ចំណុះមជ្ឈិម ស្ថិតក្រោមការដឹកនាំផ្ទាល់របស់គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត - ក្រុងនោះ និងស្ថិតក្រោមការណែនាំមុខជំនាញពីក្រសួងត្រួតពិនិត្យ ។

— គណៈកម្មាធិការត្រួតពិនិត្យស្រុក ទីរួមខេត្ត ខណ្ឌ ស្រុកជាយក្រុង " កន្លែងចាំបាច់និងមានលទ្ធភាព ស្ថិតក្រោមការដឹកនាំផ្ទាល់របស់គណៈកម្មាធិការប្រជាជនបដិវត្តស្រុក ទីរួមខេត្ត ខណ្ឌ ស្រុកជាយក្រុងនោះ និងស្ថិតក្រោមការណែនាំមុខជំនាញពីស្ថាប័នត្រួតពិនិត្យថ្នាក់លើ ។

មាត្រា ២.— គណៈកម្មាធិការត្រួតពិនិត្យទីស្តីការរដ្ឋមន្ត្រី ស្ថាប័នថ្នាក់ប្រហាក់ប្រហែលទីស្តីការរដ្ឋមន្ត្រី ខេត្ត - ក្រុង ចំណុះមជ្ឈិម ស្រុក ទីរួមខេត្ត ខណ្ឌ ស្រុកជាយក្រុង មានភារកិច្ចដូចតទៅ :

ក— ត្រួតពិនិត្យដោយម៉ឺងម៉ាត់ការអនុវត្តគោលការណ៍ គោលនយោបាយផែនការ សារាចរ សេចក្តីសំរេចរបស់ថ្នាក់លើ និងថ្នាក់ខ្លួន ។

ខ – ទទួលពិនិត្យដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ពលរដ្ឋ អោយបានស្របតាមច្បាប់ស្តីពីការទទួលពិនិត្យដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ពលរដ្ឋ ដែលរដ្ឋសភាអនុម័តកាលពីថ្ងៃទី ២០ សីហា ១៩៨២ ។

គ – ណែនាំមុខជំនាញត្រួតពិនិត្យ និងការពិនិត្យដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ពលរដ្ឋ ដល់គណៈកម្មាធិការត្រួតពិនិត្យថ្នាក់ក្រោម និងគណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាជនតាមមូលដ្ឋាន ។

មាត្រា ៣.— គណៈកម្មាធិការត្រួតពិនិត្យទីស្តីការរដ្ឋមន្ត្រី ស្ថាប័នថ្នាក់ប្រហាក់ប្រហែលទីស្តីការរដ្ឋមន្ត្រី ខេត្ត - ក្រុង ចំណុះមជ្ឈិម ស្រុក ទីរួមខេត្ត ខណ្ឌ ស្រុកជាយក្រុង មានសិទ្ធិ :

ក - ស្នើរដ្ឋមន្ត្រី ប្រធានស្ថាប័នថ្នាក់ប្រហាក់ប្រហែលទីស្តីការរដ្ឋមន្ត្រី និង ប្រធានគណៈកម្មាធិការប្រជាជនបដិវត្ត ដើម្បីចាត់តាំងការងារត្រួតពិនិត្យ ចាត់តាំងគណៈប្រតិភូ ឬ កម្មាភិបាលអោយចុះត្រួតពិនិត្យតាមផ្នែក តាមថ្នាក់របស់ខ្លួន ។

ខ— កោះប្រជុំការងារ ដើម្បីរួមពិនិត្យបញ្ហាដែលមានពាក់ព័ន្ធដល់ការងារត្រួតពិនិត្យ

គ — សំណូមពរនាយកដ្ឋាន មន្ទីរ អង្គភាពដែលពាក់ព័ន្ធ អោយផ្តល់ព័ត៌មាន និងឯកសារចាំបាច់ដែលទាក់ទងដល់ការងារត្រួតពិនិត្យ ផ្តល់កម្មាភិបាលអោយចូលរួមសហការតាមសំណូមពរត្រួតពិនិត្យ និងបង្កលក្ខណៈអោយកម្មាភិបាលត្រួតពិនិត្យ ជួបប្រាស្រ័យទាក់ទងផ្ទាល់ជាមួយមហាជន ។

ឃ — នៅពេលចាំបាច់ ប្រធានគណៈកម្មាធិការគ្រប់ថ្នាក់ មានសិទ្ធិផ្អាកជាបណ្តោះអាសន្ននូវការអនុវត្តទាំងឡាយណា ដែលពិនិត្យឃើញថា កំពុងតែ ឬ រៀបបង្កឡើងនូវមហន្តរាយដល់នយោបាយសេដ្ឋកិច្ចរដ្ឋ ឬជីវភាពរស់នៅរបស់ប្រជាជន ដែលស្ថិតក្នុងលទ្ធកិច្ច រួចរាយការណ៍ជូនថ្នាក់លើរបស់ខ្លួន ។

ង — ក្រោយការពិនិត្យមួយលើក ។ មានសិទ្ធិសន្និដ្ឋានលើការធ្វើត្រូវ ឬ ការធ្វើខុស និងលើកសំណូមពរ លើកសរសើរជូនរង្វាន់ កែលំអ ដាក់វិន័យ ។

គណៈកម្មាធិការត្រួតពិនិត្យ មិនជ្រៀតជ្រែកចូលក្នុងសកម្មភាពជំនុំជំរះរបស់តុលាការ និងអយ្យការឡើយ ។

សិទ្ធិអំណាចខាងលើនេះ មិនយកមកអនុវត្តចំពោះអង្គភាពយោធា អង្គភាពនគរបាល និងឃ្លាំងធនាគារឡើយ ។ ក្នុងករណីចាំបាច់ដែលត្រូវត្រួតពិនិត្យអង្គភាពខាងលើនេះ គឺអាស្រ័យដោយគណៈកម្មាធិការប្រជាជនបដិវត្តចេញសេចក្តីសំរេច ។

មាត្រា ៤ . — អង្គភាពដែលត្រូវត្រួតពិនិត្យ ត្រូវសហការជាមួយគណៈប្រតិភូ ឬកម្មាភិបាលត្រួតពិនិត្យ ដើម្បីធានាអោយសកម្មភាពត្រួតពិនិត្យ បានសំរេចលទ្ធផលល្អ ។

ក្រោយពីបានទទួលការសន្និដ្ឋាន និងសំណូមពររបស់គណៈកម្មាធិការត្រួតពិនិត្យ អង្គភាពដែលត្រូវត្រួតពិនិត្យត្រូវទទួលអនុវត្តរួចរាយការណ៍អំពីលទ្ធផលជូនរដ្ឋមន្ត្រី ឬប្រធានគណៈកម្មាធិការប្រជាជនបដិវត្ត និងរាយការណ៍ជូនស្ថាប័នត្រួតពិនិត្យ ។

មាត្រា ៥ . — អង្គការចាត់តាំងគណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់រួមមាន :

ក — គណៈកម្មាធិការត្រួតពិនិត្យទីស្តីការរដ្ឋមន្ត្រី និងស្ថាប័នថ្នាក់ប្រហាក់ប្រហែលនៅមជ្ឈិមមានប្រធាន ០១ រូប និង អនុប្រធានជួយក្នុងការងារ ថ្នាក់ស្មើនាយកដ្ឋាន ។

ខ — គណៈកម្មាធិការត្រួតពិនិត្យខេត្ត - ក្រុង មានប្រធាន ០១ រូប ជាសមាជិកគណៈកម្មាធិការប្រជាជនបដិវត្ត និងអនុប្រធានជួយក្នុងការងារ ថ្នាក់ស្មើអនុប្រធានមន្ទីរជុំវិញខេត្ត - ក្រុង ។

គ — គណៈកម្មាធិការត្រួតពិនិត្យស្រុក ទីរួមខេត្ត ខណ្ឌ ស្រុកជាយក្រុង មានសមាជិកគណៈកម្មាធិការប្រជាជនបដិវត្ត មួយរូប ទទួលបន្ទុកការងារនេះ និងមានអនុប្រធាន មួយរូប ទទួលជំនាញ ។

មាត្រា ៦. — ក្របខ័ណ្ឌកម្មាភិបាល បុគ្គលិក កម្មករ ធ្វើការងារត្រួតពិនិត្យគ្រប់ថ្នាក់ទូទាំងប្រទេស អាស្រ័យដោយរដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យ ស្នើឡើងក្រុមប្រឹក្សារដ្ឋមន្ត្រី ពិនិត្យសំរេច ក្រោយពីការឯកភាពពីគណៈចាត់តាំងមជ្ឈិម និងក្រសួងផែនការ ។

បើពិនិត្យឃើញថាចាំបាច់ត្រូវផ្លាស់ប្តូរប្រធាន ឬអនុប្រធាន គណៈកម្មាធិការត្រួតពិនិត្យទៅអង្គភាពផ្សេងៗ នោះ ត្រូវមានការឯកភាពពីស្ថាប័នត្រួតពិនិត្យថ្នាក់លើផ្ទាល់ ។

មាត្រា ៧. — អនុក្រឹត្យលេខ ៣៣ អ.ន.ក្រ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៨៣ ស្តីពីការចាត់តាំងបណ្តាញត្រួតពិនិត្យខេត្ត-ក្រុងជុំវិញមជ្ឈិម ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៨. — ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងត្រួតពិនិត្យ ក្រសួងផែនការ បណ្តាក្រសួង ខេត្ត-ក្រុង ដែលមានទំនាក់ទំនង មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ។

មាត្រា ៩. — អនុក្រឹត្យនេះមានអានុភាពគតិយុត្តចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ។

ភ្នំពេញ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៨៧

ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី

ប្រធាន

ហត្ថលេខា និង ត្រា

ហ៊ុន សែន

អនុក្រឹត្យ លេខ ១៦ អ.ន.ក្រ

ស្ដីពីការចាត់តាំងគណៈកម្មាធិការ ត្រួតពិនិត្យ របស់ប្រជាជននៅមូលដ្ឋាន

ក្រុមប្រឹក្សារដ្ឋមន្ត្រី

– បានឃើញរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

– បានឃើញច្បាប់ ស្ដីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យ លេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២ ។

– បានឃើញក្រឹត្យ-ច្បាប់ លេខ ៣១ ក្រ.ច ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៨៧ ស្ដីពីការបង្កើតទីស្ដីការរដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យ ។

– បានឃើញក្រឹត្យ-ច្បាប់លេខ ០៧ ក្រ.ច ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៨២ ស្ដីពីសមត្ថកិច្ច និង នីតិវិធីនៃការធ្វើច្បាប់ និង បទបញ្ជា ។

– តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យ ។

សំរេច

មាត្រា ១ .- បង្កើតអង្គការត្រួតពិនិត្យរបស់មហាជនមួយ នៅតាមបណ្ដាមូលដ្ឋាន ឃុំ សង្កាត់ សហគ្រាសផលិតកម្ម អាជីវកម្ម មន្ទីរពេទ្យ សាលារៀន . . . ណាដែលចាំបាច់ និងមានលទ្ធភាពអោយឈ្មោះថា « គណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាជន » ។

គណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាជន ស្ថិតក្រោមការចាត់តាំង និងបញ្ជាដឹកនាំដោយផ្ទាល់ពីរដ្ឋអំណាចមូលដ្ឋាន ឬ ប្រធានអង្គភាពនៅទីនោះ និង ស្ថិតក្រោមការណែនាំមុខជំនាញពីគណៈកម្មាធិការត្រួតពិនិត្យរបស់ខ្លួន ។

មាត្រា ២ .- គណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាជន មានភារកិច្ច ៖

ក – តាមដានត្រួតពិនិត្យជាប្រចាំ នូវរាល់សកម្មភាពរបស់បុគ្គលម្នាក់ ៗ នៅអង្គភាព ឬ មូលដ្ឋានរបស់ខ្លួនក្នុងការអនុវត្តបណ្ដាគោលការណ៍ គោលនយោបាយ ច្បាប់របស់រដ្ឋ ជាពិសេស

គោលនយោបាយ ស្តីពីរបបគ្រប់គ្រងសេដ្ឋកិច្ច បណ្តាបញ្ហាដែលទាក់ទងដល់ជីវភាពស្មារតី និងសម្ភារៈរបស់កម្មាភិបាល បុគ្គលិក កម្មករ និង ប្រជាជន ។

ខ – ចូលរួមមតិជាមួយប្រធានអង្គភាព ឬ រដ្ឋអំណាចមូលដ្ឋាន ក្នុងការពិនិត្យ និងដោះស្រាយរាល់បណ្តឹងតវ៉ា និងបរិហាររបស់ពលរដ្ឋ ដែលស្ថិតក្នុងសមត្ថកិច្ចនៃអង្គភាពនោះដោះស្រាយ ។

មាត្រា ៣ .— គណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាជន មានសិទ្ធិអំណាចដូចតទៅ ៖

ក — មានសិទ្ធិសំណូមពរកម្មាភិបាល បុគ្គលិក កម្មកររដ្ឋអោយផ្តល់នូវឯកសារសភាពការណ៍ដែលពាក់ព័ន្ធដល់ការងារត្រួតពិនិត្យ ។ មានសិទ្ធិជួបដោយផ្ទាល់ជាបុគ្គល ឬ សមូហភាពមហាជនតាមអង្គភាពនីមួយ ៗ ដើម្បីស្វែងយល់ និង ពិភាក្សាបណ្តាបញ្ហាដែលត្រូវត្រួតពិនិត្យ ។

ខ – មានសិទ្ធិសន្និដ្ឋាន ការធ្វើត្រូវ ឬ ខុស ចំពោះបណ្តាករណីដែលបានត្រួតពិនិត្យហើយ និងសំណើអោយអង្គភាពនោះ មានវិធានការដោះស្រាយអោយបានសមស្រប ។

គ – មានសិទ្ធិរាយការណ៍ដោយផ្ទាល់ បណ្តាកិច្ចការដែលខ្លួនអនុវត្តជូនគណៈកម្មាធិការត្រួតពិនិត្យ ថ្នាក់លើ ។ ប្រសិនបើជួបប្រទះការលំបាកក្នុងការងារ មានសិទ្ធិសំណូមពរដោយផ្ទាល់ចំពោះថ្នាក់លើ ដើម្បីដោះស្រាយ ។

មាត្រា ៤ . – អង្គការចាត់តាំង និងរបៀបរបបធ្វើការងាររបស់គណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាជន កំណត់ដូចខាងក្រោម ៖

ក . គណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាជន របស់រោងចក្រ សហគ្រាសផលិតកម្ម អាជីវកម្ម មន្ទីរពេទ្យ សាលារៀន ... អាស្រ័យដោយតំណាងកម្មករ បុគ្គលិកជ្រើសតាំង ប្រធានអង្គភាពពិនិត្យ និងសំរេច ។

គណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាជន ឃុំ សង្កាត់ អាស្រ័យដោយរណសិរ្ស អង្គការមហាជននៅទីនោះ ឧទ្ទេសនាម គណៈកម្មាធិការប្រជាជនបដិវត្តពិនិត្យ សំរេច ។

ខ – គណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាជន មានពី ៥ ទៅ ១១ នាក់ ក្រៅពីនេះមានចាត់តាំងភ្នាក់ងារត្រួតពិនិត្យនៅតាមក្រុមហ៊ុន និងក្រុមប្រជាជន ដោយឡែកបណ្តាសហគ្រាស ក្រុមហ៊ុនអាជីវកម្មធំ ។ ត្រូវចាត់តាំងបន្ថែមក្រុមត្រួតពិនិត្យរបស់ប្រជាជន ។ គណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាជន និងភ្នាក់ងារត្រួតពិនិត្យ មានអាណត្តិក្នុងរយៈពេល ១ ឆ្នាំ ។

គ . គណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាជន ធ្វើការតាមរបបសមូហភាពដឹកនាំ បុគ្គលទទួលខុសត្រូវ ។

មាត្រា ៥.- អ្នកដែលត្រូវបានជ្រើសរើសចូលក្នុង គណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាជនត្រូវមានលក្ខណសម្បត្តិដូចតទៅ ៖

ក- គោរពអនុវត្តន៍បណ្តាគោលនយោបាយ ច្បាប់របស់រដ្ឋ និង បទបញ្ជាផ្ទៃក្នុងរបស់អង្គភាពនោះបានល្អ ។

ខ- មានទំនាក់ទំនងល្អ និងត្រូវបានមហាជននៅទីនោះមានជំនឿទុកចិត្ត ។

គ- មានអាកប្បកិរិយាស្មោះត្រង់ និងសត្យានុម័តនៅក្នុងពេលវាយតម្លៃ និងសន្និដ្ឋាន ។

ឃ- ស្ម័គ្រចិត្តចូលរួមបំពេញភារកិច្ចត្រួតពិនិត្យ ដោយគ្មានទទួលប្រាក់បៀវត្ស ។

មាត្រា ៦.- ប្រធានអង្គភាព និងរដ្ឋអំណាចនៅមូលដ្ឋាននោះ ត្រូវបង្កលក្ខណៈងាយស្រួលអោយគណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាជន ធ្វើការងារបានល្អ មិនត្រូវផ្លាស់ប្តូរ ប្រធាន ឬ អនុប្រធានគណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាជន ដែលកំពុងបំពេញភារកិច្ចក្នុងអាណត្តិ ។ បើក្នុងករណីចាំបាច់ដែលត្រូវផ្លាស់ប្តូរប្រធាន ឬ អនុប្រធាននោះ ត្រូវមានការយល់ព្រមពីគណៈកម្មាធិការត្រួតពិនិត្យថ្នាក់លើផ្ទាល់ ។

មាត្រា ៧.- សមមិត្តរដ្ឋមន្ត្រី ឬ សមមិត្តប្រធានស្ថាប័នស្មើក្រសួងនៅមជ្ឈិម និង សមមិត្តប្រធានគណៈកម្មាធិការប្រជាជនបដិវត្តគ្រប់ខេត្ត-ក្រុង មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ។

មាត្រា ៨.- រដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យ មានភារកិច្ចណែនាំតាមដានត្រួតពិនិត្យ និង ដាស់តឿនការអនុវត្តអនុក្រឹត្យនេះ ។

មាត្រា ៩.- អនុក្រឹត្យនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

ភ្នំពេញ, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៨៧

ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី

ប្រធាន

ហត្ថលេខា និង ត្រា

ហ៊ុន សែន

អនុក្រឹត្យ លេខ ១៧ អនក្រ

ស្តីពីការចាត់តាំង និងសកម្មភាពរបស់ទីស្តីការ រដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យ

ក្រុមប្រឹក្សារដ្ឋមន្ត្រី

— បានឃើញរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

— បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យ លេខ ០៣ ក្រ ចុះថ្ងៃទី ១០ កុម្ភៈ ១៩៨២ ។

— បានឃើញក្រឹត្យ-ច្បាប់ លេខ ៣១ ក្រ.ច ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៨៧ ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យ ។

— បានឃើញក្រឹត្យ-ច្បាប់ លេខ ០៧ ក្រ.ច ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៨២ ស្តីពីសមត្ថកិច្ច និងនីតិវិធី នៃការធ្វើច្បាប់ និងបទបញ្ជា ។

— បានឃើញអនុក្រឹត្យ លេខ ០២ អ.ន.ក្រ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៨២ ស្តីពីការប្រកាសអោយប្រើលក្ខន្តិកៈនៃការចាត់តាំង និងសកម្មភាពរបស់ក្រសួងត្រួតពិនិត្យកិច្ចការរដ្ឋ ។

— តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យ ។

សំរេច

មាត្រា ១. — បង្កើតក្បាលម៉ាស៊ីនជំនួយការ ស្ថិតនៅក្រោមឱវាទរដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យរួមមាន :

១ — មន្ទីរ

២ — នាយកដ្ឋានត្រួតពិនិត្យសេដ្ឋកិច្ច ហិរញ្ញវត្ថុ

៣ — នាយកដ្ឋានត្រួតពិនិត្យអប់រំ វប្បធម៌ សង្គមកិច្ច

៤ — នាយកដ្ឋានទទួលពិនិត្យដោះស្រាយពាក្យបណ្តឹង

៥ — នាយកដ្ឋានគ្រប់គ្រងការងារត្រួតពិនិត្យប្រជាជន

៦ — សាលាមុខជំនាញត្រួតពិនិត្យថ្នាក់មធ្យម

៧ — ការិយាល័យចាត់តាំងកម្មាភិបាល ក្រោមការដឹកនាំផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យ

— មន្ទីរបណ្ណាធាយកដ្ឋាន និង សាលាមុខជំនាញត្រួតពិនិត្យ មានប្រធាន ១ រូប និងអនុប្រធានជំនួយការ ។

មាត្រា ២. — តួនាទី ភារកិច្ច ទំនាក់ទំនង និង របៀបរបបធ្វើការជាក់ស្តែងរបស់មន្ទីរបណ្តាធាយកដ្ឋាន និង សាលាមុខជំនាញត្រួតពិនិត្យ ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ អាស្រ័យដោយសមមិត្ត រដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យ កំណត់សំរេច និងដាក់ចេញអោយអនុវត្ត ។

ដោយឡែកក្របខ័ណ្ឌកម្មាភិបាល បុគ្គលិក កម្មករ របស់អង្គភាពក្រោមឱវាទ អាស្រ័យដោយរដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យ ស្នើឡើងក្រុមប្រឹក្សារដ្ឋមន្ត្រីពិនិត្យសំរេចក្រោយពីបានការឯកភាពពីគណៈចាត់តាំងមជ្ឈិម និងក្រសួងផែនការ ។

មាត្រា ៣. — បណ្តាស្ថាប័នគ្រប់ថ្នាក់ដែលត្រូវត្រួតពិនិត្យ មានភារកិច្ច រួមសហការជាមួយនិងកម្មាភិបាល ឬ គណៈប្រតិភូត្រួតពិនិត្យ ដើម្បីជួយនិងធានាអោយការងារត្រួតពិនិត្យ និង ការងាររបស់ស្ថាប័នខ្លួនទទួលបានលទ្ធផលល្អ ។

ក្នុងកំឡុង ១៥ ថ្ងៃយ៉ាងយូរ ចាប់តាំងពីពេលទទួលបានការសន្និដ្ឋាន និង សំណើទាំងឡាយរបស់រដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យ ស្ថាប័ន ឬអង្គភាពដែលបានត្រួតពិនិត្យ ត្រូវរាយការណ៍អោយបានច្បាស់លាស់នូវមតិរបស់ខ្លួន ជូនរដ្ឋមន្ត្រីក្រសួងត្រួតពិនិត្យ ។ បើក្នុងករណីមិនឯកភាព ក៏ត្រូវជូនដំណឹងអោយបានទាន់ពេលវេលា និងរាយការណ៍ឡើងស្ថាប័នគ្រប់គ្រងថ្នាក់លើរបស់ខ្លួន ។

មាត្រា ៤. — ដើម្បីអនុវត្តភារកិច្ចត្រួតពិនិត្យ ក្រសួងត្រួតពិនិត្យចាំបាច់ត្រូវរួមសហការយ៉ាងជិតស្និទ្ធជាមួយបណ្តាផ្នែក និងបណ្តាស្ថាប័ន ដែលមានទំនាក់ទំនងជាមួយ " នគរបាល អយ្យការ តុលាការ គណៈចាត់តាំងមជ្ឈិម គណៈកម្មាធិការត្រួតពិនិត្យរបស់មជ្ឈិមបក្ស ... " ដើម្បីរួមគ្នាពិគ្រោះ ពិភាក្សា សន្និដ្ឋាន និងដោះស្រាយនូវបញ្ហាសំខាន់ៗ ដែលមានទំនាក់ទំនងរួម ។

មាត្រា ៥. — ក្រសួងត្រួតពិនិត្យ ចាំបាច់ត្រូវមានការទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយបណ្តាអង្គការមហាជន បណ្តាស្ថាប័នឃោសនា ពត៌មាន ដើម្បីរួម

សហការគ្នាធ្វើគំរោងផែនការឃោសនាបំផុស និង ចាត់តាំងមហាជនអោយចូលរួមរាល់សកម្មភាពត្រួតពិនិត្យ ។

មាត្រា ៦.— អនុក្រឹត្យ លេខ ០២ អនក្រ ចុះថ្ងៃទី ១៩ មីនា ១៩៨២ ស្តីពីការប្រកាសអោយប្រើលក្ខន្តិកៈនៃការចាត់តាំង និង សកម្មភាពរបស់ក្រសួងត្រួតពិនិត្យកិច្ចការរដ្ឋ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៧.— ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងត្រួតពិនិត្យ ក្រសួងផែនការ និង ស្ថាប័នគ្រប់ថ្នាក់ដែលមានទំនាក់ទំនង មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ។

មាត្រា ៨.— អនុក្រឹត្យនេះ មានអានុភាពគតិយុត្តិចាប់ពីថ្ងៃដែលប្រកាសផ្សាយជាសាធារណៈ ។

ភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៨៣

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

ប្រធាន

ហត្ថលេខា និង ត្រា

ហ៊ុន សែន

២_ សេចក្តីសំរេច

សេចក្តីសំរេច លេខ ៦០ ស.ស.រ

ស្តីពីការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ និងការជ្រើសរើសចូលរៀនថ្នាក់ទី ៩ នៃមធ្យមសិក្សាកំរិត ២

ក្រុមប្រឹក្សារដ្ឋមន្ត្រី

— បានឃើញរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

— បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ កុម្ភៈ ១៩៨២ ។

— បានឃើញក្រឹត្យ - ច្បាប់លេខ ០៤ ក្រ.ច.ក្រ.ប្រ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៨០ ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ ។

— បានឃើញក្រឹត្យ - ច្បាប់លេខ ៣០ ក្រ. ច ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ។

— តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ ។

សំរេច

ប្រការ១ : ការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ និងប្រឡងជ្រើសរើសសិស្សចូលរៀនថ្នាក់ទី ៩ នៃមធ្យមសិក្សាកំរិត ២ ត្រូវធ្វើរួមជាមួយគ្នាតែមួយដងនៅចុងឆ្នាំសិក្សានីមួយ ៗ ។

សម័យប្រឡងត្រូវកំណត់ដោយក្រសួងអប់រំ ។

ប្រការ២ : មណ្ឌលប្រឡងត្រូវសំរេចដោយក្រសួងអប់រំ តាមសំណើរបស់មន្ទីរអប់រំខេត្ត - ក្រុងដោយមានយោបល់ឯកភាពរបស់គណៈកម្មាធិការប្រជាជន - បដិវត្តខេត្ត - ក្រុង ។

ប្រការ៣ ៖ លក្ខណៈវិនិច្ឆ័យដែលអាចសុំចុះឈ្មោះជាបេក្ខជនប្រឡងបានគឺ ៖

– សិស្សសាលារៀនចំណេះទូទៅដែលបានរៀនចប់កម្មវិធីសិក្សាថ្នាក់ទី៨ នៃមធ្យមសិក្សាកំរិត ១ " អតីតសិស្សថ្នាក់ទី ៧ នៃកំរិតសិក្សាទី ២ " ។

– អតីតសិស្សដែលបានប្រឡងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ " សញ្ញាប័ត្រកំរិតសិក្សាទី ២ " នាសម័យប្រឡងឆ្នាំកន្លងផុតទៅមួយឆ្នាំ មុនសម័យប្រឡងដែលកំពុងប្រព្រឹត្តទៅ ។

– អតីតសិស្សដែលប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាកំរិត១ " សញ្ញាប័ត្រកំរិតសិក្សាទី ២" ចំណេះទូទៅ នាសម័យប្រឡងដែលឆ្នាំកន្លងផុតទៅមួយឆ្នាំ មុនសម័យប្រឡងដែលកំពុងប្រព្រឹត្តទៅ " បេក្ខជនប្រភេទចុងក្រោយនេះ ពុំមានប្រកាសលទ្ធផលប្រឡងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ ទេ " ។

ប្រការ៤ ៖ បេក្ខជនដែលសុំចុះឈ្មោះប្រឡង ត្រូវបំពេញសុំណុំលិខិតតាមការណែនាំ និងតាមគំរូរបស់ក្រសួងអប់រំ ។ បេក្ខជនត្រូវដាក់ពាក្យសុំប្រឡងនិងសុំចូលរៀនសាលាមធ្យមសិក្សាកំរិត ២ ណាមួយក្នុងខេត្ត-ក្រុង របស់ខ្លួនតាមការបែងចែករបស់មន្ទីរអប់រំខេត្ត - ក្រុង ដែលបានប្រកាសផ្សាយជាសាធារណៈមុនពេលដាក់ពាក្យសុំប្រឡង ។ ក្នុងករណីដែលបេក្ខជនចង់ជ្រើសរើសសាលាមធ្យមសិក្សាកំរិត ២ ណាមួយក្នុងខេត្ត - ក្រុង ដើម្បីប្រឡងចូលរៀនថ្នាក់ទី ៩ ខុសពីការបែងចែករបស់មន្ទីរអប់រំ បេក្ខជនត្រូវមកដាក់ពាក្យសុំប្រឡងនៅមន្ទីរអប់រំខេត្ត - ក្រុង ។

ប្រការ៥ ៖ ខេត្ត - ក្រុង ដែលមានមណ្ឌលប្រឡង ត្រូវរៀបចំអោយមានគណៈមេប្រយោគទូទាំងខេត្ត - ក្រុង និង គណៈកម្មការត្រួតពិនិត្យកិច្ចការប្រឡងទូទាំងខេត្ត - ក្រុង ។ តាមមណ្ឌលប្រឡងនីមួយៗ ត្រូវមានគណៈមេប្រយោគនិងគណៈកម្មការត្រួតពិនិត្យកិច្ចការប្រឡង ។

អង្គការចាត់តាំងនិងសកម្មភាពរបស់គណៈមេប្រយោគ និងគណៈកម្មការត្រួតពិនិត្យកំណត់ដោយរដ្ឋមន្ត្រីក្រសួងអប់រំ ។

ប្រការ៦ ៖ សមាសភាព និងបរិមាណគណៈមេប្រយោគប្រឡងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ ត្រូវសំរេចដោយក្រសួងអប់រំតាមសំណើរបស់មន្ទីរអប់រំខេត្ត - ក្រុង ដោយមានយោបល់ឯកភាពពីគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត - ក្រុង ។

ប្រការ៧ : មុននឹងប្រកាសលទ្ធផលប្រឡងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត - ក្រុង ត្រូវតែងតាំងគណៈកម្មការសំរាប់ជ្រើសរើសសិស្សអោយចូលរៀនថ្នាក់ទី ៩ នៃមធ្យមសិក្សាកំរិត ២ ដែលត្រូវបន្តការងារជាបន្ទាន់ក្រោយពីការប្រកាសលទ្ធផលប្រឡងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ ។ គណៈកម្មការនេះត្រូវពិនិត្យនិងធ្វើការជ្រើសរើសសិស្ស ដោយគោរពតាមលក្ខខណ្ឌដូចខាងក្រោម :

១ — ជ្រើសរើសក្នុងចំណោមអ្នកប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ ដែលបានសុំចូលរៀនមធ្យមសិក្សាកំរិត ២ ហើយដែលស្ថិតក្នុងកំរិតអាយុត្រូវចូលរៀនថ្នាក់ទី ៩ ។

២ — ជ្រើសរើសដោយបញ្ចូលពិន្ទុអាទិភាព ដែលបេក្ខជនមានជាមួយពិន្ទុសរុបនៃការប្រឡងហើយធ្វើចំណាត់ថ្នាក់ពិន្ទុពីខ្ពស់មកទាប រហូតដល់គ្រប់ចំនួនកំណត់ដែលត្រូវជ្រើសរើស ។

៣ — ក្នុងករណីពិសេស សិស្សដែលរៀនពូកែ ហើយបានពិន្ទុទាបក្នុងការប្រឡង ឬសិស្សដែលមានពិន្ទុសរុបស្មើគ្នាក្នុងការប្រឡង ការជ្រើសរើសត្រូវផ្អែកលើការពិនិត្យសៀវភៅសិក្ខាគារិកដើម្បីសំរេចអោយចូលរៀនថ្នាក់ទី ៩ ។

សមាសភាពនៃគណៈកម្មការជ្រើសរើសសិស្សចូលរៀនថ្នាក់ទី ៩ ត្រូវមានដូចតទៅ :

— តំណាងគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត - ក្រុង និង ជាប្រធានគណៈមេប្រយោគទូទាំងខេត្ត - ក្រុង ប្រធាន

— ប្រធានមន្ទីរអប់រំខេត្ត - ក្រុង និង ជាអនុប្រធានគណៈមេប្រយោគទូទាំងខេត្ត - ក្រុង អនុប្រធាន

— តំណាងគណៈកម្មការត្រួតពិនិត្យប្រចាំខេត្ត - ក្រុង សមាជិក

— ប្រធានមណ្ឌលប្រឡងទាំងអស់ សមាជិក

— នាយកសាលារៀនមធ្យមសិក្សាកំរិត ១ និងកំរិត ២ សមាជិក

ចំពោះខេត្ត-ក្រុងដែលមានសាលាមធ្យមសិក្សាកំរិត ២ " សាលាកំរិតសិក្សាទី ៣ " ច្រើនកន្លែង គណៈកម្មាការជ្រើសរើសសិស្សចូលរៀនថ្នាក់ទី ៩ អាចរៀបចំអោយមានអនុគណៈកម្មការជ្រើសរើសសិស្សចូលរៀនថ្នាក់ទី ៩ សំរាប់សាលាមធ្យមសិក្សាកំរិត ២ នីមួយ ៗ តាមលំនាំខាងលើដែរ ។

ចំពោះសាលាមធ្យមសិក្សាកំរិត ២ ក្រោមឱវាទផ្ទាល់នៃក្រសួងអប់រំ សមាសភាពគណៈកម្មការជ្រើសរើសសិស្សចូលរៀនថ្នាក់ទី ៩ ត្រូវសំរេចដោយក្រសួងអប់រំ ។

លទ្ធផលនៃការជ្រើសរើសនឹងត្រូវប្រកាសជាបន្ទាន់ ក្រោយពីបានការយល់ព្រមពីក្រសួងអប់រំ ។

ប្រការ ៨ : គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង មានភារកិច្ចទទួលខុសត្រូវក្នុងដំណើរការ និង ការប្រព្រឹត្តទៅនៃការប្រឡង " សណ្តាប់ធ្នាប់ ជីវភាព មធ្យោបាយ សម្ភារៈ " ដើម្បីអោយការអនុវត្តកិច្ចការប្រឡងបានល្អប្រសើរ និង ប្រកបដោយគតិយុត្តិធម៌ ។

ប្រការ ៩ : ក្រសួងអប់រំត្រូវធ្វើការណែនាំលំអិត ដើម្បីអនុវត្តកិច្ចការប្រឡងអោយមានប្រសិទ្ធភាព និង មានភារកិច្ចចាត់តាំងសមាសភាពគណៈមេប្រយោគ និង គណៈកម្មការត្រួតពិនិត្យកិច្ចការប្រឡងទូទាំងប្រទេស ។

ប្រការ ១០ : ចំណាយផ្សេង ៗ ក្នុងការប្រឡងត្រូវទទួលបន្ទុកដោយថវិការដ្ឋ ។

ប្រការ ១១ : ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងអប់រំ បណ្តាក្រសួងដែលពាក់ព័ន្ធនិងគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសំរេចនេះ ។

ប្រការ ១២ : សេចក្តីសំរេចនេះមានប្រសិទ្ធភាពក្រោយពីថ្ងៃចុះហត្ថលេខា ។

ភ្នំពេញ, ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៨៧

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

ប្រធាន

ហត្ថលេខា និង ត្រា

ហ៊ុន_សែន

សេចក្តីសំរេចលេខ ៦៤ ស.ស.រ

ស្តីពីការបណ្តុះបណ្តាលអ្នកគ្រូមត្តេយ្យ
" ៧ បូក ១ "

ក្រុមប្រឹក្សារដ្ឋមន្ត្រី

– បានឃើញរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

– បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២ ។

– បានឃើញក្រឹត្យ-ច្បាប់លេខ ០៤ ក្រ.ច.ក្រ.ប្រ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៨០ ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ ។

– បានឃើញអនុក្រឹត្យ លេខ ២៤ អ.ន.ក្រ ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ១៩៨៤ ស្តីពីការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស ។

– បានឃើញសេចក្តីសំរេច លេខ ២០៦ ស.ស.រ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៨៥ ស្តីពីការបង្កើតសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម ។

– តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយក្រសួងអប់រំរៀបចំដំណើរការបណ្តុះបណ្តាលអ្នកគ្រូមត្តេយ្យរដ្ឋ និង ក្រុមសាមគ្គីតាមប្រព័ន្ធ "៧ បូក ១" រយៈពេល ១ ឆ្នាំ នៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និង នៅតាមសាលាគរុកោសល្យ និង វិក្រឹតការខេត្ត-ក្រុង មួយចំនួនដែលមានលទ្ធភាពក្នុងបណ្តាឆ្នាំខាងមុខ ។

ប្រការ ២ : ចំនួនគរុសិស្សត្រូវកំណត់ឡើង ដោយក្រសួងអប់រំ និង ក្រសួងផែនការ ។ គរុសិស្សត្រូវរស់នៅតាមរបបអន្តេវាសិក ដោយទទួលអាហារូបករណ៍ពីរដ្ឋ ។

ប្រការ ៣ : នៅពេលបញ្ចប់វគ្គបណ្តុះបណ្តាលគរុសិស្ស ត្រូវប្រឡងយកសញ្ញាប័ត្រគរុកោសល្យ ។

— គរុសិស្សដែលប្រឡងជាប់ នឹងត្រូវបានតែងតាំងជាអ្នកគ្រូមត្តេយ្យ « ៧ បូក ១ » បំរុងសមមូលនឹងក្របខ័ណ្ឌគ្រូកំរិតសិក្សា ទី ១ បំរុងផ្នែកចំណេះទូទៅតាមការកំណត់របស់រដ្ឋ ។

— គរុសិស្សដែលប្រឡងធ្លាក់ ត្រូវបានតែងតាំងជាអ្នកគ្រូមត្តេយ្យ « ៧ បូក ១ » បំរុងសមមូល នឹងក្របខ័ណ្ឌគ្រូកំរិតសិក្សា ទី ១ បំរុងផ្នែកចំណេះទូទៅ រហូតដល់សាមីជនបានប្រឡងជាប់សញ្ញាប័ត្រគរុកោសល្យជាស្ថាពរ ទើបតែងតាំងស៊ុបក្នុងក្របខ័ណ្ឌបាន ។

ប្រការ ៤ : បទបញ្ញត្តិផ្សេងៗ ស្តីអំពី

— លក្ខណៈវិនិច្ឆ័យជ្រើសរើសគរុសិស្ស

— ការណែនាំចាត់តាំងគ្រប់គ្រងបណ្តាសកម្មភាពបណ្តុះបណ្តាល

— កម្មវិធីខ្លឹមសារ និង ឯកសារបណ្តុះបណ្តាល

— ការប្រឡងបញ្ចប់ ការបណ្តុះបណ្តាល

— ការចេញសញ្ញាប័ត្រ

នឹង ត្រូវកំណត់ដោយក្រសួងអប់រំ ។

ប្រការ ៥ : ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងអប់រំ ក្រសួងផែនការ ក្រសួងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត - ក្រុង និង បណ្តាផ្នែកដែលមានការពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៨៧

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ប៊ូ ថង

សេចក្តីសំរេច លេខ ៦៨ សសរ

ស្តីពីថ្លៃលក់ចបកាប់ផលិតដោយក្រសួងឧស្សាហកម្ម

ក្រុមប្រឹក្សារដ្ឋមន្ត្រី

— បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យ លេខ ០៣ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— យោងសេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ១១០ ស.រ.ច ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៨១

— តាមសំណើរបស់ក្រសួងផែនការ

សំរេច

ប្រការ ១ : កំណត់ថ្លៃលក់រាយចបកាប់ផលិតដោយក្រសួងឧស្សាហកម្ម ជូនប្រជាកសិករ មានដូចតទៅ :

— ចបកាប់ផ្សារភ និងតក្បាលទម្ងន់ ១,២ គក្រ : ២២ រៀល

— ចបកាប់ចាក់ពុម្ពទម្ងន់ ១,៧ គក្រ : ៣០ រៀល

ប្រការ ២ : ថ្លៃប្រគល់រវាងក្រសួងឧស្សាហកម្ម និង ក្រសួងពាណិជ្ជកម្ម ស្មើនឹងថ្លៃលក់ក្នុងប្រការ ១ ដក អប្បហារ ១៦ ភាគរយ ។

ប្រការ ៣ : ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងផែនការ ក្រសួងកសិកម្ម ក្រសួងពាណិជ្ជកម្ម ក្រសួងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្ម ធនាគារជាតិនៃប្រជាជនកម្ពុជា គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត - ក្រុង មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ។

ប្រការ ៤ : — បទបញ្ញត្តិទាំងឡាយណាដែលមានពីមុនមក ហើយដែលមានខ្លឹមសារ

ផ្ទុយពីសេចក្តីសំរេចនេះត្រូវទុកជានិរាករណ៍ ។ សេចក្តីសំរេចនេះមានប្រសិទ្ធភាពអនុវត្តចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៨៧

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ជា សុទ្ធ

សេចក្តីសំរេច លេខ ៦៥ ស.ស.រ

ស្តីពី ថ្លៃលក់ ស៊ីម៉ង់ត៍

ក្រុមប្រឹក្សារដ្ឋមន្ត្រី

– បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យ លេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

– យោងស្មារតីអង្គប្រជុំគណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សារដ្ឋមន្ត្រី ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៨៧

– តាមសំណើរបស់ក្រសួងផែនការ

សំរេច

ប្រការ ១. កែប្រែថ្លៃលក់រាយស៊ីម៉ង់ត៍គ្រប់ប្រភេទ ជូនប្រជាជន សំរាប់បំរើសេចក្តីត្រូវការចាំបាច់ក្នុងការងារសាងសង់ ដូចខាងក្រោមនេះ ៖

ល.រ	ប្រភេទស៊ីម៉ងត៍	ឯកតា	ថ្លៃលក់រាយ
១	ប៉េ ៥០០	រ. តោន	៧០០០ ៛
២	ប៉េ ៤០០	–	៦០០០ ៛
៣	ប៉េ ៣០០	–	៥០០០ ៛

ប្រការ ២ : ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងផែនការ ក្រសួងគមនាគមន៍ ក្រសួងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានសំណង់ គណៈកម្មាធិការប្រជាជនបដិវត្ត បណ្ដាខេត្ត.ក្រុង ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៣ : បទបញ្ញត្តិទាំងឡាយណាដែលមានពីមុនមក ហើយដែលមានន័យផ្ទុយពីសេចក្ដីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

សេចក្ដីសំរេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ៖

ភ្នំពេញ, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៨៨

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ជា សុទ្ធ

សេចក្ដីសំរេច លេខ ៧០ ស.ស.រ

ស្ដីពី ថ្លៃលក់ ជាតិគ្រប់ប្រភេទ

ក្រុមប្រឹក្សារដ្ឋមន្ត្រី

– បានឃើញច្បាប់ ស្ដីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យ លេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

- យោងស្មារតីអង្គប្រជុំគណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សារដ្ឋមន្ត្រី ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៨៧

— តាមសំណើរបស់ក្រសួងផែនការ

សំរេច

ប្រការ ១ : ថ្លៃលក់ផ្គត់ផ្គង់បារីកន្ទុយស្មោរជូនកម្មាភិបាល បុគ្គលិក កម្មករ កងកម្លាំងប្រដាប់អាវុធ និងសន្តិសុខ ព្រមទាំងបរិមាណលក់ប្រចាំខែ ត្រូវរក្សាទុកដដែល « ៦រៀលក្នុងមួយកញ្ចប់ និង ៥ កញ្ចប់ ក្នុងម្នាក់ ក្នុងមួយខែ » ។

ប្រការ ២ : ថ្លៃលក់រាយសំរាប់មុខសញ្ញាដទៃទៀត មានដូចតទៅ .

ល.រ	មុខទំនិញ	យថាប្រភេទ	ឯកតា	ថ្លៃលក់រាយ
១	បារីរំដោះ	កន្ទុយស្មោរ	កញ្ចប់	២០រ៉ៀល
២	បារីជាតិ	—	—	១១រ៉ៀល
៣	បារី ៧ មករា	—	—	១០រ៉ៀល
៤	បារីជ័យជំនះ	—	—	៣០រ៉ៀល
៥	បារីអប្សរា	គ្មានកន្ទុយស្មោរ	—	៦រ៉ៀល
៦	បារីសូរិយា	—	—	៤រ៉ៀល
៧	បារីបាយ័ន	—	—	៤រ៉ៀល

ប្រការ ៣ : ក្រសួងពាណិជ្ជកម្ម និង ក្រសួងហិរញ្ញវត្ថុ ត្រូវសហការណែនាំអនុវត្តការទូទាត់ និង ការលក់ អោយបានត្រឹមត្រូវតាមមុខសញ្ញា និង តាមកំរិតថ្លៃដែលមានចែង ក្នុង ប្រការ ១ និង ប្រការ ២ ខាងលើ ។

ប្រការ ៤ : សេចក្តីសំរេចទាំងឡាយដែលមានពីមុនមក ហើយមានន័យផ្ទុយនឹងសេចក្តីសំរេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

សេចក្តីសំរេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់តាំងពីថ្ងៃចុះហត្ថលេខា ។

ភ្នំពេញ, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៨៧

ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ជា សុទ្ធ

៣_ សារាចរ

សារាចរលេខ ០៣ ស.រ

ស្តីពី ការគ្រប់គ្រងសាច់ប្រាក់ ចំពោះកងកម្លាំងប្រដាប់អាវុធ

ដើម្បីបង្កើនការធានាចំពោះការផ្គត់ផ្គង់ នូវបណ្តាមុខទំនិញគ្រប់ប្រភេទដូចជា : គ្រឿងបន្ទាស់ ប្រេងឥន្ធនះ សម្ភារៈបរិក្ខារ វត្ថុធាតុដើម ស្បៀងអាហារ គ្រឿងឧបភោគបរិភោគ ឧបករណ៍ប្រើប្រាស់ ឱសថ ... ។ល។ " ហៅកាត់ថា : មុខសម្ភារៈ " បានគ្រប់គ្រាន់តាមផែនការ សំរាប់ជីវភាពកងទ័ព និង បង្កើនការគ្រប់គ្រងសាច់ប្រាក់ក្នុងកងកម្លាំងប្រដាប់អាវុធ ក្រុមប្រឹក្សារដ្ឋមន្ត្រីកំណត់នូវវិធានការមួយចំនួន ដូចខាងក្រោមនេះ :

១ — ក្រសួងការពារប្រទេស ទទួលរ៉ាប់រងធ្វើផែនការប្រើប្រាស់បណ្តាមុខសម្ភារៈ និង ធ្វើផែនការ ថវិកាសំរាប់កិច្ចការពារប្រទេសតាមការកំណត់របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលក្នុងនោះត្រូវចែងអោយបានច្បាស់នូវចំណែកដែលត្រូវចំណាយជាមុខសម្ភារៈ និង ចំណែកដែលចំណាយជាសាច់ប្រាក់ ។ ដើម្បីធ្វើផែនការសាច់ប្រាក់ និង មុខសម្ភារៈអោយរិតតែបានល្អ និង ស្របតាមសភាពការណ៍ជាក់ស្តែង ក្រសួងផែនការនិងក្រសួងទាំងឡាយ ដែលមានការពាក់ព័ន្ធ មានភារកិច្ចជួយក្រសួងការពារប្រទេស ដូចខាងក្រោមនេះ :

— ចំពោះថវិកា គឺក្រសួងហិរញ្ញវត្ថុជួយរៀបចំ ។

— ចំពោះមុខសម្ភារៈ គឺក្រសួងផែនការ និង ក្រសួងទាំងឡាយដែលពាក់ព័ន្ធជួយរៀបចំ ។

— ចំពោះផែនការចំណាយជាសាច់ប្រាក់គឺធនាគារជាតិជួយរៀបចំ ។

២ — ក្រោយពីផែនការត្រូវអនុម័តហើយ ក្រសួងការពារប្រទេស ត្រូវគិតគូរបែងចែកអោយបណ្តាអង្គភាពតាមរបៀបគ្រប់គ្រងរបស់ក្រសួងខ្លួន ។ ពេលបែងចែកទៅអោយបណ្តាអង្គភាពក្រោមឱវាទក៏ត្រូវចែងយ៉ាងច្បាស់លាស់នូវចំណែកដែលចំណាយជាមុខសម្ភារៈ និង ចំណែកដែលចំណាយជាសាច់ប្រាក់ដែរ ។

ចំពោះផែនការសាច់ប្រាក់ ក្រសួងការពារប្រទេស និងតំបន់យោធាទាំងឡាយ ពេលផ្ញើទៅអោយ

អង្គភាព ក៏ត្រូវផ្ញើជូនធនាគារជាតិមជ្ឈិមដើម្បីជ្រាប និង មានផែនការបញ្ជូនសាច់ប្រាក់ជូនកងទ័ពអោយបានគ្រប់គ្រាន់ទាន់ពេលវេលា ។ បណ្ដាអង្គភាពកងកម្លាំងប្រដាប់អាវុធ ដែលបើកគណនីនៅធនាគារជាតិថ្នាក់ណា ត្រូវជូនដំណឹងដល់ធនាគារជាតិថ្នាក់នោះ ដើម្បីកត់ត្រាទុកនូវផែនការសាច់ប្រាក់ដែលស្នើដកដោយមានចែងច្បាស់នូវចំណែកដែលចំណាយជាសាច់ប្រាក់ ។

បើអង្គភាពណាមិនបានផ្ញើជូនជាមុននូវផែនការសាច់ប្រាក់ទេ នោះធនាគារជាតិមានសិទ្ធិមិនយល់ព្រមអោយបើកប្រាក់ឡើយ ។

៣ — បណ្ដាខ្ទង់ទិញ-លក់ សេវាកម្មជាមួយបណ្ដាស្ថាប័នរដ្ឋ និងអង្គការសេដ្ឋកិច្ចដែលមានគណនី នៅធនាគារជាតិ គឺត្រូវតែទូទាត់ដោយបង្វែរ ។

អង្គភាពកងកម្លាំងប្រដាប់អាវុធដែលជាអ្នកទិញ ត្រូវចុះកិច្ចសន្យាជាមួយបណ្ដាអង្គភាពលក់ ហើយត្រូវទូទាត់ភ្លាមក្រោយពេលបានទទួលមុខសម្ភារៈហាមទិញជឿលក់ជឿ និងប្រើប្រាស់សាច់ប្រាក់លើកលែងតែក្នុងករណីពិសេស ។ បើទិញមុខសម្ភារៈនៅឯតំបន់ដទៃត្រូវប្រើមូលប្បទានប័ត្របញ្ជូនប្រាក់ ហាមកាន់យកសាច់ប្រាក់ទៅទិញមុខសម្ភារៈ ហាមបុរេប្រទានខុសពីរបបទូទាត់ដោយមិនប្រើសាច់ប្រាក់ ដែលបានចេញផ្សាយជាធរមាន ។

៤ — បណ្ដាថ្នាក់គ្រោងទូទាត់នៃថវិកា ដែលជាអង្គភាពអាណាព្យាបាល មានភារៈកំណត់បញ្ជាក់អំពីកំរិតសំណល់បេឡាសាច់ប្រាក់ដែលចាំបាច់អោយបណ្ដាអង្គភាពមូលដ្ឋាន ទន្ទឹមនឹងនេះក៏ត្រូវជូនដំណឹង ដល់ធនាគារជាតិដែលអង្គភាពមូលដ្ឋាននោះបើកគណនីផង ។

៥ — ក្រសួងហិរញ្ញវត្ថុ មានភារៈផ្ដល់បញ្ជាចំណាយអោយទាន់ពេលវេលាជូនក្រសួងការពារប្រទេសតាមគ្រាកំណត់ ដោយសំអាងលើផែនការថវិកាដែលបានអនុម័តហើយ ។

៦ — ក្រសួងទាំងឡាយដែលមានការពាក់ព័ន្ធដល់ការផ្គត់ផ្គង់មុខសម្ភារៈ ជូនក្រសួងការពារប្រទេសមានភារៈ ផ្គត់ផ្គង់មុខសម្ភារៈគ្រប់គ្រាន់ និង ទាន់ពេលវេលាតាមផែនការប្រចាំឆ្នាំត្រីមាស ដែលបានអនុម័ត មិនត្រូវបើកសាច់ប្រាក់ជូនកងទ័ពជំនួសមុខសម្ភារៈឡើយ ។

៧ — ធនាគារជាតិ មានភារៈផ្គត់ផ្គង់សាច់ប្រាក់គ្រប់គ្រាន់ និង ទាន់ពេលវេលាតាមផែនការដែលបានអនុម័តនៅកន្លែងដែលអង្គភាពទ័ពបើកគណនី ។

៨ — ក្រសួងការពារប្រទេស តំបន់យោធាទាំងឡាយ ត្រូវមានផែនការចាត់ចែងត្រួតពិនិត្យកិច្ចប្រតិបត្តិនូវរបបគ្រប់គ្រងសាច់ប្រាក់ចំពោះបណ្ដាអង្គភាពថ្នាក់ក្រោម ។ ប្រធាននៃបណ្ដាអង្គភាពត្រូវទទួលខុសត្រូវចុះត្រួតពិនិត្យដោយផ្ទាល់ ក្នុងមួយត្រីមាស មួយដង អំពីកិច្ចប្រតិបត្តិនូវ

របបគ្រប់គ្រងសាច់ប្រាក់របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ហើយផ្ញើកំណត់ហេតុនៃការត្រួតពិនិត្យជូនថ្នាក់លើ ព្រមទាំងផ្ញើជូនជាដំណឹងដល់ធនាគារជាតិ ដែលអង្គភាពត្រូវត្រួតពិនិត្យបើកគណនីផង ។ ក្នុងករណីចាំបាច់ ក្រសួងហិរញ្ញវត្ថុដោយមានការអនុញ្ញាតពីក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវរួមសហការជាមួយក្រសួងត្រួតពិនិត្យកិច្ចការរដ្ឋ ក្រសួងផែនការ ធនាគារជាតិ និងក្រសួងការពារប្រទេស បង្កើតគណៈកម្មការត្រួតពិនិត្យ ដើម្បីចាត់ចែងត្រួតពិនិត្យចំពោះអង្គភាពមួយចំនួន ។

៩ – សារាចរនេះ មានអានុភាពគតិយុត្តិចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។ ក្នុងដំណើរអនុវត្ត បើមានជួបការលំបាកស្មុគស្មាញ បណ្ដាក្រសួងដែលមានការពាក់ព័ន្ធ ត្រូវរាយការណ៍ជូនក្រុមប្រឹក្សារដ្ឋមន្ត្រីជាបន្ទាន់ ដើម្បីពិនិត្យដោះស្រាយ ។

ភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៨៧

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

ប្រធាន

ហត្ថលេខា និង ត្រា

ហ៊ុន សែន

៤ — សេចក្តីណែនាំ

សេចក្តីណែនាំលេខៈ ០១ ស.ណ.ន

ស្តីពីការអនុវត្តដំណើរការបោះឆ្នោតបំពេញបន្ថែម សមាជិក រដ្ឋសភា

ក្រុមប្រឹក្សារដ្ឋមន្ត្រី

— អនុវត្តតាមសេចក្តីសំរេច របស់ការិយាល័យនយោបាយមជ្ឈិមបក្ស លេខ ៤១ ស.ស.រ.ម.ឈ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៨៦ ។

— អនុវត្តតាមក្រឹត្យលេខ ១៣ ក្រ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៨៧ អនុញ្ញាតអោយមានការបោះឆ្នោតបំពេញបន្ថែម សមាជិករដ្ឋសភា មណ្ឌលកំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ចាម ស្វាយរៀង សៀមរាប-ឧត្តរមានជ័យ និង ស្ទឹងត្រែង នៅថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ១៩៨៧ ខាងមុខ ។

ដើម្បីធានាការអនុវត្តភារកិច្ចដ៏សំខាន់នេះ អោយទទួលបានលទ្ធផលល្អ ក្រុមប្រឹក្សារដ្ឋមន្ត្រីសូមធ្វើការណែនាំបណ្តាក្រសួង ស្ថាប័នជុំវិញមជ្ឈិម និង គណៈកម្មាធិការប្រជាជនបដិវត្តខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ស្វាយរៀង កំពង់ចាម សៀមរាប-ឧត្តរមានជ័យ និង ស្ទឹងត្រែង ដូចខាងក្រោម ៖

១ — ក្រសួងហិរញ្ញវត្ថុ ត្រូវផ្តល់ថវិកាជូនក្រុមប្រឹក្សាបោះឆ្នោត ទន្ទឹមនឹងនោះត្រូវបញ្ជាមន្ទីរហិរញ្ញវត្ថុខេត្តទាំង ៦ អោយដោះស្រាយបានទាន់ពេលវេលានូវថវិកាចំណាយសំរាប់ការងារចាត់តាំង ទិញសម្ភារៈ ដើម្បីបំរើការបោះឆ្នោតនៅតាមបណ្តាមូលដ្ឋាន ។ ធនាគារត្រូវជួយសំរួលអោយបណ្តាអង្គភាពរៀបចំការបោះឆ្នោត បានដកសាច់ប្រាក់ដល់ដៃ ដើម្បីបំរើការងារបោះឆ្នោត ។

២ — ក្រសួងផែនការ និង ក្រសួងពាណិជ្ជកម្ម ត្រូវពិនិត្យ និង ជួយសំរួលដល់អង្គភាពរៀបចំការបោះឆ្នោតក្នុងការសុំទិញសម្ភារៈចាំបាច់សំរាប់បំរើការងារបោះឆ្នោត ។

៣ – ក្រសួងឃោសនាការវប្បធម៌ ត្រូវសហការជាមួយគណៈឃោសនាអប់រំជម្រិម ណែនាំដល់បណ្ដាអង្គភាពឃោសនាការវប្បធម៌ ពតិមានគ្រប់ជាន់ថ្នាក់ ដើម្បីចាត់តាំងធ្វើបដាពាក្យស្លោក តុបតែងលំអការិយាល័យបោះឆ្នោត និង ចាត់តាំងសិល្បៈ កីឡាកំសាន្ត ដើម្បីអបអរសាទរថ្ងៃបោះឆ្នោត ។

ក្រសួងឃោសនាការវប្បធម៌ ត្រូវប្រគល់ភារកិច្ចអោយបណ្ដារោងពុម្ព ដើម្បីជួយសំរួលក្នុងការបោះពុម្ពរាល់ឯកសារ ស្ដីពីការបោះឆ្នោតសមាជិករដ្ឋសភា ស្របតាមចំនួនកំណត់ និងទាន់ពេលវេលា ។

ស្ថានីយវិទ្យុផ្សាយសម្លេង វិទ្យុទូរទស្សន៍ ខ្សែភាពយន្ត និង បណ្ដាអ្នកកាសែត ត្រូវទាក់ទងស្និតរម្មូតជាមួយគណៈឃោសនាអប់រំជម្រិម ទទួលមតិណែនាំ ដើម្បីឃោសនា បំរើអោយការបោះឆ្នោត ។

៤ – ក្រសួងមហាផ្ទៃ ត្រូវមានផែនការជាក់ស្ដែង ណែនាំអោយមន្ទីរនគរបាលខេត្តទាំង ៦ មានវិធានការការពារធានាសណ្ដាប់ធ្នាប់សន្តិសុខរបៀបរៀបរយសំរាប់ថ្ងៃបោះឆ្នោត ។

៥ – ក្រសួងការពារប្រទេស សហការជាមួយក្រសួងមហាផ្ទៃ ដើម្បីចាត់តាំងការការពារអោយបានហ្មត់ចត់ទៅមុន និង នៅក្នុងពេលបោះឆ្នោត និង ត្រូវមានផែនការជាក់ស្ដែង ដើម្បីណែនាំ អោយគណៈបញ្ជាការយោធាខេត្តទាំង ៦ មានវិធានការទប់ទល់ខ្មាំងបំផ្លិចបំផ្លាញ បង្កើនការត្រួតពិនិត្យយាមកាម ធានាអោយបានសុវត្ថិភាពជាដាច់ខាត ។

– ចំពោះបណ្ដាអង្គភាពកងទ័ព ដែលបោះទីតាំងក្នុងទឹកដីខេត្តជាមូលដ្ឋានបោះឆ្នោតបំពេញបន្ថែម ក្រសួងការពារប្រទេស ត្រូវណែនាំអោយគណៈបញ្ជាការអង្គភាពបង្កើតគណៈកម្មការបោះឆ្នោត ធ្វើស្ថិតិអ្នកមានសិទ្ធិបោះឆ្នោត ចាត់តាំងជាការិយាល័យបោះឆ្នោតដោយឡែកត្រឹមត្រូវតាមក្រឹត្យ-ច្បាប់ ស្ដីពីការបោះឆ្នោត និង សេចក្ដីណែនាំជាក់ស្ដែង របស់ក្រុមប្រឹក្សាបោះឆ្នោតដើម្បីដំណើរការ ការបោះឆ្នោត ។

៦ – ដើម្បីធានាអនុវត្តល្អការបោះឆ្នោត ក្រសួងទានា ត្រូវចាត់តាំងកម្មាភិបាលអោយចូលរួមក្នុងគណៈកម្មការមុខជំនាញ តាមសំណូមពររបស់ក្រុមប្រឹក្សាបោះឆ្នោត ទន្ទឹមនឹងនោះត្រូវបញ្ជាអោយអង្គភាពក្រោមឱវាទខ្លួននៅក្នុងខេត្តទាំង ៦ ទាក់ទងជិតស្និទ្ធជាមួយគណៈកម្មាធិការប្រជាជនបដិវត្ត និង គណៈកម្មាធិការបោះឆ្នោតនៅមូលដ្ឋាន ដើម្បីផ្លាស់ប្ដូរយោបល់ជាក់ស្ដែងនូវបណ្ដាផែនការការងារ ។

៧ – គណៈកម្មាធិការប្រជាជនបដិវត្តខេត្តទាំង ៦ ត្រូវចាត់ទុកការងារនេះ ជាការងារមួយចាំបាច់ និង បន្ទាន់ មានអត្ថន័យនយោបាយខ្ពស់ ។ ក្រោយពេលដែលទទួលបានសេចក្ដីសំរេច របស់ការិយាល័យនយោបាយ និង សេចក្ដីណែនាំនានា របស់ក្រុមប្រឹក្សាបោះឆ្នោត គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត ត្រូវកោះអញ្ជើញប្រជុំរួម មានប្រធានអង្គភាព និង ផ្នែកដែលមានពាក់ព័ន្ធ "ប្រធានគណៈកម្មាធិការរណសិរ្ស ប្រធានមន្ទីរនគរបាល មន្ទីរហិរញ្ញវត្ថុ មន្ទីរឃោសនាការ វប្បធម៌ ពត៌មាន មន្ទីរឃោសនាអប់រំ គណៈបញ្ជាការយោធាខេត្ត ប្រធាន ឬ អនុប្រធាន គណៈកម្មាធិការប្រជាជនបដិវត្ត ទីរួមខេត្ត ។ល។" ដើម្បីផ្សព្វផ្សាយបណ្ដាក្រឹត្យ-ច្បាប់ស្ដីពីការបោះឆ្នោត សេចក្ដីសំរេចរបស់ការិយាល័យនយោបាយ ក្រឹត្យអនុញ្ញាតអោយមានការបោះឆ្នោត និង បណ្ដាលិខិតណែនាំរបស់ក្រុមប្រឹក្សាបោះឆ្នោត របស់ក្រុមប្រឹក្សាទូទាំងប្រទេសរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា ពិភាក្សាផែនការចាត់តាំងការបោះឆ្នោត ។ ត្រូវបង្កើតគណៈកម្មាធិការបោះឆ្នោតដូចក្រឹត្យ - ច្បាប់បានកំណត់ និង កសាងកម្មវិធីការងារអោយបានលំអិត កំណត់ច្បាស់អង្គភាព ដែលត្រូវអនុវត្តថ្ងៃ ខែ ត្រូវសំរេច ដើម្បីធ្វើជាមូលដ្ឋានក្នុងការតាមដាន និង ត្រួតពិនិត្យ ។

៨— ត្រូវបើកវគ្គរៀនសូត្ររយៈពេលខ្លីនៅខេត្ត ទីរួមខេត្ត សង្កាត់ ដើម្បីផ្សព្វផ្សាយបណ្ដាលិខិតរបស់បក្ស និង រដ្ឋ ដូចបានពោលខាងលើ ពមទាំងបំប៉នយ៉ាងល្អិតល្អន់អោយបងប្អូនយល់អឹងច្បាស់លាស់ ពីរបៀបដំណើរការបោះឆ្នោតនេះ ។ នៅថ្នាក់ខេត្ត, សង្កាត់ ក្រៅពីគណៈកម្មាធិការបោះឆ្នោត និងគណកម្មការបោះឆ្នោតត្រូវចាត់តាំងក្រុមជំនួយការមួយ រួមមានកម្មាភិបាលដែលមានកំរិតវប្បធម៌ នយោបាយបង្គួរ និង មានការពិសោធន៍ល្អ "បណ្ដាអនុគណៈកម្មការមុខជំនាញនិង ក្រុមប្រតិបត្តិការ" ។

៩ – ថ្នាក់សង្កាត់ គឺ ជាកន្លែងចាត់តាំងដោយផ្ទាល់នូវការបោះឆ្នោតសមាជិករដ្ឋសភា ។ ដូច្នេះ ខេត្ត ទីរួមខេត្ត ត្រូវណែនាំបណ្ដា គណៈកម្មាធិការប្រជាជនបដិវត្តសង្កាត់ បើកការប្រជុំជាមួយផ្នែក ដែលមានការពាក់ព័ន្ធក្នុងសង្កាត់ ដើម្បីស្រាវជ្រាវច្បាស់លាស់បណ្ដាលិខិតណែនាំរបស់ក្រុមប្រឹក្សាទូទាំងប្រទេសរណសិរ្ស សាមគ្គីកសាងការពារមាតុភូមិ ក្រុមប្រឹក្សាបោះឆ្នោតបំពេញបន្ថែម គណៈកម្មការណែនាំការបោះឆ្នោតរបស់គណៈកម្មាធិការបក្សខេត្ត គណៈកម្មាធិការបោះឆ្នោតខេត្ត ផ្សព្វផ្សាយខ្លឹមសារបណ្ដាឯកសារកសាងកម្មវិធីការងារលំអិត ពិសេសយកចិត្ត

ទុកដាក់ ការធ្វើបញ្ជី និង បិទផ្សាយបញ្ជីរាយនាមអ្នកមានសិទ្ធិបោះឆ្នោត ចាត់តាំងការិយាល័យបោះឆ្នោត និង លើកទឹកចិត្តអ្នកមានសិទ្ធិបោះឆ្នោត អោយទៅរៀនសូត្របណ្ណាឯកសារ និង ទៅបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា ដែលជាតំណាងរបស់ខ្លួន អោយបានគ្រប់ចំនួន ។

ភ្នំពេញ, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៩៨៧

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ម៉ូ ~ ៥០

II – ការងារបណ្ដាក្រសួង

១– ក្រសួងអប់រំ

ប្រកាស

ប្រកាស លេខ ០១ អ.រ.ប្រ.ក

ស្ដីពីការកែប្រែ និង បំពេញបន្ថែម ប្រកាសលេខ ០១អរ.ចតប្រ ចុះ ថ្ងៃទី ១២ ខែ មិថុនា ១៩៨៥

រដ្ឋមន្ត្រីក្រសួងអប់រំ

– បានឃើញប្រកាសលេខ ០១ អរ.ចតប្រ ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៨៥ ស្ដីពីការជ្រើសរើសសិស្ស និស្សិត អោយចូលរៀនក្នុងគ្រឹះស្ថានឧត្ដមសិក្សា និង សិក្សាឯកទេស ក្នុងប្រទេស និង ទៅសិក្សានៅបរទេស

— តាមសំណើរបស់ប្រធាននាយកដ្ឋានឧត្ដមសិក្សា និង សិក្សាឯកទេស

សំរេច

ប្រការ ១ ; កែប្រែនិងបំពេញបន្ថែម មាត្រា ១៣ នៃប្រកាសលេខ ០១ អរ.ចតប្រ ចុះថ្ងៃទី ១២ - មិថុនា - ៨៥ .មាត្រា ១៣ ចាស់ : បេក្ខជនទាំងអស់ផ្អែកទៅតាមមុខជំនាញនីមួយៗដែលខ្លួនបានជ្រើសយកត្រូវប្រឡងជ្រើសរើសតាមវិញ្ញាសាប្រឡងដូចតទៅ ៖

ពោះអ្នកដែលជ្រើសយកមុខជំនាញវិទ្យាសាស្ត្រមូលដ្ឋាន ដូចជា : " គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា " ឬវិទ្យាសាស្ត្របច្ចេកទេស ត្រូវប្រឡងវិញ្ញាសាសរសេរបីដូចតទៅ : គណិតវិទ្យា រូបវិទ្យា និង គីមីវិទ្យា ។

២ - ចំពោះអ្នកដែលជ្រើសយកមុខជំនាញ ជីវវិទ្យា មុខជំនាញវេជសាស្ត្រ ឱសថសាស្ត្រ

ឬ កេរ្សត្រសាស្ត្រ ត្រូវប្រឡងវិញ្ញាសាសរសេរបីគឺ : គណិតវិទ្យា គីមីវិទ្យា និង ជីវវិទ្យា ។

៣ – ចំពោះអ្នកដែលជ្រើសយកមុខជំនាញវិទ្យាសាស្ត្រ សេដ្ឋកិច្ច ត្រូវប្រឡងវិញ្ញាសាសរសេរបីគឺ : គណិតវិទ្យា វប្បធម៌ទូទៅ និងភូមិវិទ្យាសេដ្ឋកិច្ច ។

៤ – ចំពោះអ្នកដែលជ្រើសយកមុខជំនាញវិទ្យាសាស្ត្រសង្គម ត្រូវប្រឡងវិញ្ញាសាសរសេរបីគឺ អក្សរសិល្ប៍ ភូមិវិទ្យា និងប្រវត្តិវិទ្យា ឬ វប្បធម៌ទូទៅ ។

ចំពោះអ្នកដែលជ្រើសយកមុខជំនាញដែលទាមទារនូវសម្បទា ឬ ឧបនិស្ស័យ ខាងវិជ្ជាជីវៈ « ដូចជា សិល្បៈ ភាសាបរទេស » ត្រូវប្រឡងវិញ្ញាសាពីរ ក្នុងបណ្តាចំណុចទាំងបួនខាងលើវិញ្ញាសាត្រួតពិនិត្យសម្បទាពិសេសមួយទៀតរបស់សាមីជន ។ ក្រសួងអប់រំនឹងធ្វើការណែនាំដោយឡែក ចំពោះករណីនេះ ។

វិញ្ញាសានៃការប្រឡងជ្រើសរើសទាំងអស់ត្រូវអោយមូលវិចារណ៍តាមពិន្ទុ ដប់លើដប់ $\frac{10}{10}$ ក្រសួង ឬ អង្គការដែលមានសាលាក្រោមឱវាទជាអ្នកធ្វើប្រធានវិញ្ញាសាសំរាប់ការប្រឡងជ្រើសរើសនេះ ។

ក្រសួង ឬ អង្គការដែលមានសាលាក្រោមឱវាទ អាចប្រគល់កិច្ចការជ្រើសរើស ប្រធានវិញ្ញាសាប្រឡង និងការធ្វើការាងអត្រាពិន្ទុដល់ក្រុមពិសេសមួយ ដែលមានសមាជិកចាត់តាំងដោយថ្នាក់ដឹកនាំនៃក្រសួង ឬ អង្គការដែលមានសាលាក្រោមឱវាទ ហើយក្រុមពិសេសនោះត្រូវទទួលខុសត្រូវនូវការថែរក្សាការសំងាត់នៃប្រធានវិញ្ញាសាប្រឡង ។

មាត្រា – ១៣ ថ្មី :

បេក្ខជនទាំងអស់ ផ្អែកទៅតាមមុខជំនាញនីមួយ ៗ ដែលខ្លួនបានជ្រើសយក ត្រូវប្រឡងជ្រើសរើសតាមវិញ្ញាសាប្រឡងដូចតទៅ ៖

១ – ចំពោះអ្នកដែលជ្រើសយកមុខជំនាញវិទ្យាសាស្ត្រមូលដ្ឋានដូចជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ឬ ជាវិទ្យាសាស្ត្របច្ចេកទេស ត្រូវប្រឡងវិញ្ញាសាបី គឺ :

– សីលធម៌នយោបាយ

– គណិតវិទ្យា

– រូបវិទ្យា និង គីមីវិទ្យា

២ – ចំពោះអ្នកដែលជ្រើសយកមុខជំនាញជីវវិទ្យា វេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តសាស្ត្រ ឬ កេរ្សត្រសាស្ត្រ ត្រូវប្រឡងវិញ្ញាសាសរសេរ ៣ គឺ :

- សីលធម៌នយោបាយ
- គណិតវិទ្យា
- ជីវវិទ្យា និងគីមីវិទ្យា

៣ – ចំពោះអ្នកដែលជ្រើសយកមុខជំនាញវិទ្យាសាស្ត្រសេដ្ឋកិច្ច ត្រូវប្រឡងវិញ្ញាសាសរសេរ ៣ គឺ :

- សីលធម៌នយោបាយ
- គណិតវិទ្យា
- ភូមិវិទ្យាសេដ្ឋកិច្ច

៤ – ចំពោះអ្នកដែលជ្រើសយកមុខជំនាញវិទ្យាសាស្ត្រសង្គម ត្រូវប្រឡងវិញ្ញាសាសរសេរ ៣ គឺ :

- សីលធម៌នយោបាយ
- អក្សរសិល្ប៍
- ភូមិវិទ្យា និង ប្រវត្តិវិទ្យា

– ចំពោះអ្នកដែលជ្រើសយកមុខជំនាញដែលទាមទារ សម្បទា ឬ ឧបនិស្ស័យខាងវិជ្ជាជីវៈដូចជា សិល្បៈ កាសាបរទេសត្រូវប្រឡងវិញ្ញាសាសរសេរ ៣ គឺ :

– វិញ្ញាសាត្រួតពិនិត្យសម្បទាពិសេសមួយរបស់សាមីជន និង វិញ្ញាសាឯទៀតក្នុងបណ្តាវិញ្ញាសានៃចំណុចទាំង ៤ ខាងលើ ហើយដែលក្នុងវិញ្ញាសា ២ នោះមានវិញ្ញាសាសីលធម៌នយោបាយមួយ ។

ក្រសួងអប់រំនឹងធ្វើការណែនាំដោយឡែកចំពោះការណ៍នេះ ។

វិញ្ញាសានីមួយៗ ត្រូវអោយមូលវិចារណ៍តាមពិន្ទុ ដប់លើដប់ $\frac{1}{10}$ និង មានរយៈពេលធ្វើចំពោះកំរិតឧត្តម ៣ ម៉ោង ចំពោះកំរិតមធ្យម កម្មករជំនាញ និងកំរិតបឋម ២ ម៉ោង ។

ចំពោះវិញ្ញាសាដែលមាន ២ មុខវិជ្ជាបញ្ចូលគ្នា ត្រូវតែដោយសាស្ត្រាចារ្យកំណែផ្សេងមុខវិជ្ជានីមួយៗ ដោយដាក់មូលវិចារណ៍ពិន្ទុមួយមុខវិជ្ជាទាបបំផុត ០ និងខ្ពស់បំផុត ៥ ។ មុខវិជ្ជាទាំងពីរនោះត្រូវបូកពិន្ទុបញ្ចូលគ្នា ។

ក្រសួង ឬ អង្គការដែលមានសាលាក្រោមឱវាទ ជាអ្នកធ្វើប្រធានវិញ្ញាសាសំរាប់ការប្រឡងជ្រើសរើសនេះ ។

ក្រសួង ឬ អង្គការដែលមានសាលាក្រោមឱវាទ អាចប្រគល់កិច្ចការជ្រើសរើសប្រធានវិញ្ញាសាប្រឡង និង ការធ្វើតារាងពិគ្រោះដល់ក្រុមពិសេសមួយដែលមានសមាជិកចាត់តាំងដោយថ្នាក់ដឹកនាំនៃក្រសួង ឬ អង្គការដែលមានសាលាក្រោមឱវាទ ហើយក្រុមពិសេសនោះត្រូវទទួលខុសត្រូវនូវការថែរក្សាការសំងាត់នៃប្រធានវិញ្ញាសាប្រឡង ។

ប្រការ ២ : សល់ពីនោះឥតមានប្រែប្រួល ឬ បន្ថែមអ្វីឡើយ

ប្រធានមន្ទីរ ប្រធាននាយកដ្ឋានឧត្តមសិក្សា មធ្យមសិក្សាបច្ចេកទេស និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ ប្រធាននាយកដ្ឋានដទៃទៀតនៃក្រសួងអប់រំ នាយកនៃគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេសទាំងអស់ គណៈកម្មាធិការជ្រើសរើសសិស្សឯកទេសទាំងអស់របស់ក្រសួង អង្គការ ឬ ខេត្ត - ក្រុង ត្រូវទទួលខុសត្រូវក្នុងការអនុវត្តបទបញ្ជានេះ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៨៧

រដ្ឋមន្ត្រីក្រសួងអប់រំ

ហត្ថលេខា និង ត្រា

ប៉ែន ~ ណាវុធ

សារាចរណែនាំ

សារាចរណែនាំលេខ : ០១ អរ.ចនម

ស្តីពីការជ្រើសរើសសិស្សអោយចូលរៀនថ្នាក់ទី ៦ នៃសាលារៀន មធ្យមសិក្សាកំរិត ១ ចំណេះទូទៅ

– យោងក្រឹត្យ - ច្បាប់លេខ ៣០ ក្រ.ច ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ស្តីពីប្រព័ន្ធអប់រំ ១១ ឆ្នាំ

– យោងលិខិតលេខ ៥៣០ សជណ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៨៤ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការប្រឡងចូលរៀនថ្នាក់ទី ៥ និង ទី ៨ នៃសាលារៀនចំណេះទូទៅ

– យោងសេចក្តីណែនាំរបស់ក្រសួងអប់រំ លេខ ១៣៥៨ អរ.ចចម ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៨៦ ស្តីពីការជ្រើសរើសអោយចូលរៀនថ្នាក់ទី ៥ នៃសាលាចំណេះទូទៅ ។

ចាប់ពីឆ្នាំសិក្សា ១៩៨៦ - ៨៧ នេះតទៅ ការជ្រើសរើសសិស្សអោយចូលរៀនថ្នាក់ទី ៦ នៃសាលារៀនមធ្យមសិក្សាកំរិត ១ ចំណេះទូទៅ ត្រូវអនុវត្តតាមការណែនាំដូចខាងក្រោមនេះ ៖

ក្រោយពីប្រកាសលទ្ធផលនៃការប្រឡងវិញ្ញាបនប័ត្របឋមសិក្សា ផ្នែកចំណេះទូទៅ សមមិត្តប្រធានមន្ទីរអប់រំគ្រប់ខេត្ត - ក្រុង និង សមមិត្ត នាយកសាលារៀនចំណេះទូទៅ ក្រោមនាទផ្ទាល់ក្រសួងអប់រំ ត្រូវផ្សព្វផ្សាយពត៌មានដល់សិស្សដែលប្រឡងជាប់ទាំងនោះពីការដាក់ពាក្យសុំចូលរៀនថ្នាក់ទី ៦ នៃមធ្យមសិក្សាកំរិត ១ ដែលមន្ទីរអប់រំ ខេត្ត - ក្រុង បានកំណត់បែងចែកសមស្របជាមុន តាមផែនការ ។

– កាលបរិច្ឆេទនៃការដាក់ពាក្យសុំចូលរៀននេះ ត្រូវចាប់ផ្តើមពីថ្ងៃទី *១៥ កក្កដា ដល់ថ្ងៃទី ១០ សីហា ។*

I – *សំណុំលិខិតសុំចូលរៀន*

បេក្ខជនត្រូវធ្វើពាក្យសុំចូលរៀនថ្នាក់ទី ៦ មួយច្បាប់ទៅនាយកសាលារៀនមធ្យមសិក្សាកំរិត ១ ដែលសិស្សត្រូវសុំចូលរៀនតាមការបែងចែករួចហើយរបស់មន្ទីរអប់រំ ខេត្ត - ក្រុង តាមរយៈថានានុក្រម « គំរូជូនភ្ជាប់ » ។

ចំពោះបេក្ខជនជាកូនយុទ្ធជន - កូនកម្មាភិបាល បុគ្គលិក - កូនប្រជាជនដែលបានពលីជីវិតក្នុងបុព្វហេតុបដិវត្ត កុមារកំព្រាទាំងឪពុក ម្ដាយ ក្នុងរបបប៉ុលពតនិងកូនជនជាតិភាគតិចដែលមានដើមកំណើតនៅតំបន់ព្រៃភ្នំ ត្រូវមានលិខិតបញ្ជាក់ពីរដ្ឋអំណាចថ្នាក់ឃុំ "សង្កាត់ " ភ្ជាប់មកជាមួយផង។

នាយកសាលារៀនបឋមសិក្សាដើមរបស់បេក្ខជន ជាអ្នកទទួលខុសត្រូវក្នុងការទទួលពាក្យ និង សំណុំលិខិតទាំងនេះ ហើយជាអ្នករៀបចំធ្វើបញ្ជីចាំបាច់ទាំងឡាយដែលនឹងត្រូវបញ្ជូនទៅនាយកសាលារៀនមធ្យមសិក្សាកំរិត ១ តាមរយៈការិយាល័យអប់រំស្រុក - ខណ្ឌ និង មន្ទីរអប់រំខេត្ត - ក្រុង អោយបានទាន់ពេលវេលាសំរាប់ជាឯកសារប្រជុំពិភាក្សាជ្រើសរើស ។

ចំពោះសិស្សដែលបានកំណត់ថា ជាសិស្សថ្នាក់ទី ៤ ពិសេសពេលមុននេះ " ប្រសិនបើមាន " ត្រូវធ្វើបញ្ជីដាច់ដោយឡែក ដោយគោរពតាមខ្លឹមសារនៃការណែនាំលេខ ១២៥៨ អរ. ចទម ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ១៩៨៥ ពោលគឺសិស្សដែលមានមធ្យមភាគប្រចាំឆ្នាំពីមធ្យមឡើងទៅ ហើយមានវិន័យ និង អាយុសមស្រប ត្រូវបានជ្រើសរើសអោយចូលរៀនថ្នាក់ទី ៦ ដោយស្វ័យប្រវត្តិ ។

សិស្សដែលមានមធ្យមភាគក្រោមមធ្យម តែមានកិរិយាមារយាទសមស្របប្រសិនបើខេត្ត-ក្រុង មានលទ្ធភាពជ្រើសរើសបាន ត្រូវធ្វើការបំប៉នក្នុងមហាវិស្សមកាលគឺ បំប៉នយ៉ាងណាអោយសិស្សនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចរៀនថ្នាក់ទី ៦ បាន " ការបំប៉ននោះត្រូវធ្វើអោយបានមុនពេលប្រជុំជ្រើសរើស " ។

ចំពោះសាលារៀនចំណេះទូទៅ ក្រោមឱវាទផ្ទាល់ក្រសួងអប់រំ ត្រូវតំកល់សំណុំលិខិតទាំងនោះទៅសាលារួមរបស់ខ្លួន ដោយរាយការណ៍ទៅនាយកដ្ឋានចំណេះទូទៅ និង មន្ត្រីយ៍សិក្សានៃក្រសួងអប់រំ ។

I — *គោលការណ៍នៃការជ្រើសរើស*

ការជ្រើសរើស ត្រូវគោរពតាមផែនការកំណត់របស់រដ្ឋ និង ក្រសួងអប់រំសំរាប់ឆ្នាំសិក្សានីមួយៗដោយគួបផ្សំ នឹង លទ្ធភាពគ្រូនៅសាលារៀនមធ្យមសិក្សាកំរិត ១ ដោយគិតទាំងចំនួនម៉ោងបន្ថែមផង តែត្រូវចៀសវាងដាច់ខាតការដកគ្រូពីបឋមសិក្សាទៅអោយបង្រៀននៅសាលា-រៀនមធ្យមសិក្សាកំរិត ១

— ការជ្រើសរើស ត្រូវគោរពតាមចំណាត់ថ្នាក់ពិន្ទុពីខ្ពស់មកទាប និង តាមអាទិភាព ក្នុងករណីមានពិន្ទុស្មើគ្នាច្រើននាក់ ។

— កាលបរិច្ឆេទនៃការជ្រើសរើសត្រូវចាប់ផ្ដើមពីថ្ងៃទី *១៥ ដល់ថ្ងៃទី ២៥ ខែ សីហា*

ដោយគណៈកម្មការជ្រើសរើសដែលចាត់តាំងដោយគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត - ក្រុងតាមសំណើរបស់ប្រធានមន្ទីរអប់រំ ខេត្ត ក្រុង ។ ចំពោះសាលាដែលស្ថិតក្រោមឱវាទក្រសួងត្រូវជ្រើសរើសដោយគណៈកម្មការដែលតាំងដោយក្រសួង តាមសំណើរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ។

III *សមាសភាព នៃ គណៈកម្មការជ្រើសរើស*

គណៈកម្មការជ្រើសរើសនេះត្រូវបានរៀបចំអោយបានស្រេចមុនកាលបរិច្ឆេទនៃការជ្រើសរើស ហើយត្រូវមានសមាសភាពដាច់ដោយឡែកសំរាប់សាលារៀនមធ្យមសិក្សាកំរិត ១ និមួយ ៗ ដែលជាមជ្ឈមណ្ឌលនៃការសុំចូលរៀនថ្នាក់ទី ៥ របស់សិស្សក្នុង ខេត្ត - ក្រុង ។

សមាសភាព នៃ គណៈកម្មការនេះមានដូចតទៅ :

១ – ប្រធានមន្ទីរអប់រំ ឬ តំណាង ជា . . . . ប្រធាន

២ – ប្រធានការិយាល័យអប់រំស្រុក - ខណ្ឌ . . . . អនុប្រធាន

៣ – តំណាងគណៈកម្មាធិការប្រជាជនបដិវត្តស្រុក - ខណ្ឌ . . . . អនុប្រធាន

៤ – នាយកសាលារៀនមធ្យមសិក្សាកំរិត ១ . . . . . . អនុប្រធាន

៥ – នាយកសាលារៀនបឋមសិក្សាដែលមានសិស្សដាក់ពាក្យសុំចូលរៀន . . . សមាជិក

៦ – កម្មាភិបាលទទួលបន្ទុកផ្នែកការយុវជននៃសាលាមធ្យមសិក្សាកំរិត ១ សមាជិក

៧ – កម្មាភិបាលទីចាត់ការសាលារៀនមធ្យមសិក្សាកំរិត ១ មួយនាក់ លេខាកត់ត្រា

ចំពោះសាលារៀនចំណេះទូទៅក្រោមឱវាទផ្ទាល់ក្រសួងអប់រំ , នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សាមានភារកិច្ចរៀបចំដោយឡែក ។

គណៈកម្មការនេះ ត្រូវទទួលខុសត្រូវចំពោះគណៈកម្មាធិការប្រជាជនបដិវត្ត ខេត្ត-ក្រុង និង ក្រសួងអប់រំ ក្នុងករណីដែលជ្រើសរើសមិនសមស្របតាមការណែនាំនេះ ។

IV – *លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស*

ខេត្តវាលរាប : បេក្ខជនត្រូវមានអាយុ ១១ ឆ្នាំ យ៉ាងតិច និង អាយុ ១៨ យ៉ាងច្រើន គិតមកដល់បវេសនកាលឆ្នាំសិក្សាថ្មី ។

ខេត្តព្រៃភ្នំ : បេក្ខជនត្រូវមានអាយុ ១១ យ៉ាងតិច និង ១៦ ឆ្នាំ យ៉ាងច្រើនគិតមកដល់បវេសនកាលឆ្នាំសិក្សាថ្មី ។

ករណីពិសេស : ចំពោះ

– កូនយុទ្ធជនពលី កម្មាភិបាលពលី បុគ្គលិក កម្មករពលីក្នុងបុព្វហេតុបដិវត្ត ត្រូវបន្ថែមពីរពិន្ទុ « ០២ ពិន្ទុ » លើពិន្ទុសរុបនៃការប្រឡងវិញ្ញាបនប័ត្របឋមសិក្សាចំពោះទូទៅ

– កូនកំព្រាឪពុក ម្តាយ ក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត អៀង សារី ខៀវ សំផន ដែលមានប្រវត្តិរូបច្បាស់លាស់ត្រូវបន្ថែម មួយពិន្ទុកន្លះ « ១,៥០ ពិន្ទុ » ។

– កូនជនជាតិភាគតិចដើមកំណើតពីខេត្តព្រៃភ្នំ ត្រូវអនុញ្ញាតអោយចូលរៀនដោយស្វ័យប្រវត្តិ ។

– ក្នុងករណីបេក្ខជនមានពិន្ទុស្មើគ្នាច្រើននាក់ ដែលនាំអោយលើសផែនការកំណត់នោះ អាទិភាព ត្រូវបានផ្តល់បេក្ខជនណាដែលរៀនពូកែក្នុងថ្នាក់ និង មានគំនិតមារយាទល្អ ហើយមានអាយុច្រើនជាងគេ « ដោយផ្អែកលើសៀវភៅសិក្ខាគារិក ឬ ព្រឹត្តិប័ត្រពិន្ទុ » ។

V - *ការណែនាំដើម្បីធ្វើការជ្រើសរើស*

ប្រធានគណៈកម្មការជ្រើសរើសជាអ្នកអញ្ជើញសមាជិកមកប្រជុំតាមកាលបរិច្ឆេទ ដែលក្រសួងអប់រំបានកំណត់ខាងលើ ។

គណៈកម្មការនេះ មុននឹងពិភាក្សាជ្រើសរើសត្រូវសិក្សាស្រាវជ្រាវ និង ពិនិត្យបញ្ជីស្រង់ពិន្ទុប្រឡងតាមសាលារៀន បញ្ជីអនុញ្ញាតអោយចូលរៀនដោយស្វ័យប្រវត្តិ « ប្រសិនបើមាន » និងឯកសារជ្រើសរើសអោយបានជ្រួតជ្រាបជាមុន ។

ពេលពិភាក្សាជ្រើសរើស នាយកសាលាបឋមសិក្សាដែលជាសមាជិក មានភារកិច្ចបំភ្លឺអង្គប្រជុំតាមការចាំបាច់ចំពោះករណីបេក្ខជនម្នាក់ៗ ដែលមកពីសាលារបស់ខ្លួន ។

ការប្រជុំពិភាក្សាជ្រើសរើស ត្រូវបញ្ចប់សំរេចដោយកំណត់ហេតុតាមល័ក្ខការណ៍នៃអង្គប្រជុំ។ កំណត់ហេតុនោះ ត្រូវមានបញ្ជីសិស្សដែលគណៈកម្មការបានជ្រើសរើសអោយចូលរៀនថ្នាក់ទី ៦ ជាស្នាដៃចំនួន ៣ ច្បាប់ ដោយមានការយល់ព្រមពីមន្ទីរអប់រំខេត្ត-ក្រុង និងការឯកភាពពីប្រធានគណៈកម្មាធិការប្រជាជនបដិវត្ត ខេត្ត - ក្រុង ។ បញ្ជីឈ្មោះសិស្សដែលបានទទួលការយល់ព្រមពីថ្នាក់លើត្រូវបញ្ជូន មួយច្បាប់ទៅសាលារៀនមធ្យមសិក្សាកំរិត ១ ដែលសិស្សសុំចូលរៀន

– តំកល់ទុកមួយច្បាប់នៅមន្ទីរអប់រំ ខេត្ត - ក្រុង

– មួយច្បាប់ទៀតនៅការិយាល័យអប់រំស្រុក - ខណ្ឌ ។

ប្រធានមន្ទីរអប់រំខេត្ត - ក្រុង ត្រូវប្រកាសលទ្ធផល នៃការជ្រើសរើសនេះនៅសាលារៀន

មធ្យមសិក្សាកំរិត ១ ដែលសិស្សសុំចូលរៀន និង ផ្សព្វផ្សាយដល់គ្រប់សាលារៀនបឋមសិក្សារបស់សិស្សទាំងនោះជាបន្ទាន់ផង ។

សំណុំលិខិតសិស្សដែលពុំបានត្រូវជ្រើសរើសអោយចូលរៀន ត្រូវផ្ញើត្រឡប់ទៅសាលារៀនដើមវិញ ដើម្បីប្រគល់អោយសាមីជន ។

សមមិត្តប្រធានមន្ទីរអប់រំខេត្ត-ក្រុង ត្រូវធ្វើរបាយការណ៍សរុបរួម ស្តីពីការជ្រើសរើសសិស្សអោយចូលរៀនថ្នាក់ទី ៦ នៃសាលារៀនចំណេះទូទៅក្នុង ខេត្ត - ក្រុង ជា ២ ច្បាប់ ដោយបញ្ជាក់ច្បាស់លាស់ពីចំនួនសិស្សដាក់ពាក្យសុំចូលរៀន តាមសាលារៀនមធ្យមសិក្សាកំរិត ១ នីមួយ ៗ និងចំនួនសិស្សដែលសាលារៀនអាចទទួលអោយចូលរៀនដោយមានការឯកភាពពីគណៈកម្មាធិការ - ប្រជាជនបដិវត្តខេត្ត - ក្រុង ផង " គំរូជូនភ្ជាប់ " ផ្ញើទៅក្រសួងអប់រំ នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា មុនពេលបើកបវេសនកាល ។

ក្រសួងសង្ឃឹមថា សមមិត្តប្រធានមន្ទីរអប់រំ ខេត្ត - ក្រុង និង សមមិត្តនាយកសាលារៀនក្រោមឱវាទក្រសួង នឹងយកចិត្តទុកដាក់អនុវត្តន៍ខ្លឹមសារនៃសារាចរនេះអោយមានប្រសិទ្ធភាពខ្ពស់

ភ្នំពេញ,ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៨៧

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ

អនុរដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហាក់ ជួន

ខេត្ត ក្រុង ____________

ស្រុក ____________

ឃុំ ____________

សាលារៀន ______

សាធារណរដ្ឋប្រជាមានិតកម្ពុជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

បញ្ជីរាយនាមបេក្ខជនថ្នាក់ទី ៥ ពិសេស ដែលត្រូវបានជ្រើសរើសអោយចូលរៀនថ្នាក់ទី ៦ សាលារៀនចំណេះទូទៅដោយស្វ័យប្រវត្តិ

ល.រ	នាមត្រកូលនាមខ្លួន	មធ្យមភាគប្រចាំឆ្នាំ	ចំណាត់ថ្នាក់	សេចក្តីផ្សេងៗ
១		៨, ០០	១	ជ្រើសរើសដោយស្វ័យប្រវត្តិ
២		៦, ៥០	២	-ដ-
៣		៦, ៥០		
៤		៦, ០០		
៥		៥, ៥០		
៦		៤, ៥០		ជ្រើសរើសក្រោយការបំប៉ន
៧		៤, ០០		-ដ-

បញ្ឈប់បញ្ជីនេះត្រឹមលេខរៀង ____________ ចំនួនបេក្ខជន ____________ នាក់

____ *ថ្ងៃទី ____ ខែ ____ ឆ្នាំ ១៩ ____*

នាយកសាលា

បានឃើញ និង ពិនិត្យត្រឹមត្រូវ

____ *ថ្ងៃទី ____ ខែ ____ ឆ្នាំ ១៩ ____*

ប្រធានការិយាល័យអប់រំស្រុក " ខណ្ឌ "

បានឃើញ និង ឯកភាព

____ *ថ្ងៃទី ____ ខែ ____ ឆ្នាំ ១៩៨ ____*

ប្រធានមន្ទីរអប់រំខេត្ត-ក្រុង

កំណត់សំគាល់ : បញ្ជីនេះស្នើដាក់តាំងទុកនៅមន្ទីរអប់រំខេត្ត-ក្រុង " ដើម្បីជាឯកសារ "

សាធារណរដ្ឋប្រជាមានិតកម្ពុជា
ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

មន្ទីរអប់រំខេត្ត-ក្រុង ________
ស្រុក ________
ឃុំ ________
សាលារៀន ________

បញ្ជីរាយនាមបេក្ខជន ប្រឡងជាប់វិញ្ញាបនប័ត្រកំរិតសិក្សាទី ១ សំរាប់ជ្រើសរើសអោយចូលរៀនថ្នាក់ទី ៦ នៃសាលារៀន ________

ចំណេះទូទៅ

ល.រ	នាមត្រកូលនាមខ្លួន	ពិន្ទុប្រឡងសរុប	ពិន្ទុបន្ថែម	សរុបពិន្ទុ	ចំណាត់ថ្នាក់	សេចក្តីផ្សេង ៗ
១		២៨	០០	២៨	១	
២		២៥	០២	២៧	២	កូនយុទ្ធជនពលីក្នុងបុព្វហេតុបដិវត្ត
៣		២៦	០០	២៦	៣	
៤		២៤	១,៥០	២៥,៥០	៤	កុមារកំព្រាទាំងឪពុកម្ដាយក្នុងរបបប៉ុល ពត
៥		២០	០០	២០		កូនជនជាតិភាគតិចដែលមានដើមកំណើតខេត្តក្រចេះ

____ថ្ងៃទី____ខែ____ឆ្នាំ១៩៨____

នាយកសាលា

បានឃើញ និង ពិនិត្យត្រឹមត្រូវ

____ថ្ងៃទី____ខែ____ឆ្នាំ ១៩៨____

ប្រធានការិយាល័យអប់រំ ស្រុក " ខ័ណ្ឌ "

បានឃើញ និង ឯកភាព

____ថ្ងៃទី____ខែ____ឆ្នាំ ១៩៨...

ប្រធានមន្ទីរអប់រំខេត្ត

កំណត់សំគាល់ : បញ្ជីនេះស្នើដកល់ទុកនៅមន្ទីរអប់រំខេត្ត - ក្រុង ដើម្បីជាឯកសារ

សាធារណរដ្ឋប្រជាមានិតកម្ពុជា

ខេត្ត - ក្រុង

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

របាយការណ៍

ស្តីពីការជ្រើសរើសសិស្សអោយចូលរៀនថ្នាក់ទី ៦ នៃសាលារៀនចំណេះទូទៅនានាក្នុង ខេត្ត - ក្រុង សំរាប់បវេសនកាលឆ្នាំសិក្សា ១៩៨៧ - ៨៨

យោងទៅតាមខ្លឹមសារ នៃ សារាចរណែនាំរបស់ក្រសួងអប់រំលេខ ______ ចុះថ្ងៃទី ______ ខែ ______ ឆ្នាំ ១៩៨៧ ខ្ញុំសូមជំរាបសមមិត្ត រដ្ឋមន្ត្រីថា ; មន្ទីរអប់រំខេត្តបានធ្វើការជ្រើសរើសសិស្សថ្នាក់ទី ៥ ដែលប្រឡងជាប់វិញ្ញាបនប័ត្រកំរិតសិក្សាទី ១. សម័យប្រឡងថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៨៧ និង សិស្សថ្នាក់ទី ៥ ពិសេស (ប្រសិនបើមាន) ក្នុងខេត្តតាមលិខិតឧទ្ទេសនាមលេខ ______ ចុះថ្ងៃទី ______ ខែ ______ ឆ្នាំ ១៩៨ ______ បានសំរេចលទ្ធផលដូចខាងក្រោមនេះ ៖

ល.រ	សាលាមធ្យមសិក្សាកំរិត ១ ដែលទទួលសិស្សអោយចូលរៀន	ទីតាំងសាលា	ចំនួនពាក្យសុំ	ចំនួនសិស្សទទួលបាន	ផ្សេងៗ "១"
១		ទីរួមខេត្ត			
២		ទីរួមស្រុក			
៣		ឃុំ			
		សរុប			

"១" — ស្នើបញ្ជាក់ពីករណី :
- តាមផែនការកំណត់
- លើសផែនការ
- មិនគ្រប់ផែនការ

ករណីពិសេសដែលកើតមានឡើង និង ដោះស្រាយ

______

______

______

សំណូមពរ

______

______

______

______ ថ្ងៃទី ______ ខែ ______ ឆ្នាំ ១៩៨ ______

បានឃើញ និង ឯកភាព
ប្រធានគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង

ប្រធានមន្ទីរអប់រំខេត្ត - ក្រុង

២– ក្រសួងហិរញ្ញវត្ថុ

សេចក្ដីសំរេច

សេចក្ដីសំរេច លេខ : ០៤៧ . សសរ . គហវ

ស្ដីពីការកំណត់ចំណូលរដ្ឋរបស់សហគ្រាសយន្តសាស្ត្រក្រោមឱវាទក្រសួងឧស្សាហកម្ម

រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

– បានឃើញសេចក្ដីសំរេចលេខ ០៦ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៧៩ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្ត ស្ដីពីការបង្កើតក្រសួងហិរញ្ញវត្ថុ ។

– បានឃើញសារាចរលេខ ៥១ សរ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៨៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី និង សារាចរណែនាំ លេខ ០៦១ គហវ·សរ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៨៣ ស្ដីពីរបបចំណូលហិរញ្ញវត្ថុ និង របបដកប្រាក់ បង្កើតរបឡាសហគ្រាសរដ្ឋ របស់ក្រសួងហិរញ្ញវត្ថុ។

– ក្រសួងឧស្សាហកម្ម បានពិនិត្យ និង ឯកភាព ។

សំរេច

ប្រការ ១ : ត្រូវបានកែសំរួលកំរិតចំណូលរដ្ឋលើផលរបរ របស់សហគ្រាសយន្តសាស្ត្រទី ៥ . ៦ . ៧ ដែលបានកំណត់ឆាបណ្ដោះអាសន្ន ក្នុងសេចក្ដីសំរេចលេខ ១៩៦៧ គហវ ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៨៤ និងកំណត់ជាថ្មី អោយសហគ្រាសយន្តសាស្ត្រនីមួយ ៗ ក្រោមឱវាទក្រសួងឧស្សាហកម្មនូវសមាមាត្រ ដូចមានចែងក្នុងប្រការ ២ នៃ សេចក្ដីសំរេចនេះ ។

ប្រការ ២ : ប្រគល់សមាមាត្រចំណូលរដ្ឋ លើផលរបរលក់ចេញអោយសហគ្រាសយន្តសាស្ត្រទី ១ . ២ , ៣ . ៤ , ៨ · ៩ តាមកំរិតខាងក្រោម ៖

ល.រ	ឈ្មោះ សហគ្រាស	សមាមាត្រកំរិតចំណូលរដ្ឋ	ផ្សេង ៗ
១	យន្តសាស្ត្រទី ១	២០%	លើផលរបរលក់ចេញ
២	យន្តសាស្ត្រទី ២	២៥%	—
៣	យន្តសាស្ត្រទី ៣	២០%	—
៤	យន្តសាស្ត្រទី ៤	២៥%	—
៥	យន្តសាស្ត្រទី ៥	៣០%	—
៦	យន្តសាស្ត្រទី ៦	៤០%	—
៧	យន្តសាស្ត្រទី ៧	៣០%	—
៨	យន្តសាស្ត្រទី ៨	៣%	—
៩	យន្តសាស្ត្រទី ៩	២៥%	—

ប្រការ ៣ ៖ គ្រប់សហគ្រាសយន្តសាស្ត្រ មានភារកិច្ចបង់ចំណូលរដ្ឋគ្រប់ចំនួន ចូលថវិការដ្ឋក្រោយពេលទូទាត់ ។

— ក្នុងដំណើរអនុវត្ត ប្រសិនបើមានបាតុភាពសេដ្ឋកិច្ចកើតឡើងដោយខែដន្យសហគ្រាសត្រូវរាយការណ៍ជាបន្ទាន់ជូន ក្រសួងហិរញ្ញវត្ថុ ដើម្បីធ្វើការកែតម្រូវបានទាន់ពេលវេលា ។

— ចំពោះប្រាក់លំអៀងសល់ ពីប្រាក់ចំណេញកំរិតកំណត់ និង ចំណូលរដ្ឋ សហគ្រាសមានភារកិច្ចបង់ចូលថវិការដ្ឋ ក្រោមរូបភាពជាខ្ទង់ស៊ែសមភាពថ្លៃ ។

ប្រការ ៤ ៖ សេចក្តីសំរេចនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៨៧ តទៅ ។

ភ្នំពេញ, ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៨៧

ជ. រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

អនុរដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ម៉ុន សម

២– ក្រសួងហិរញ្ញវត្ថុ

សេចក្ដីសំរេច

សេចក្ដីសំរេច លេខ : ០៤៧ . សសរ . កហវ

ស្ដីពីការកំណត់ចំណូលរដ្ឋរបស់សហគ្រាសយន្តសាស្ត្រក្រោមឱវាទ ក្រសួងឧស្សាហកម្ម

រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

– បានឃើញសេចក្ដីសំរេចលេខ ០៦ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៧៩ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្ត ស្ដីពីការបង្កើតក្រសួងហិរញ្ញវត្ថុ ។

– បានឃើញសារាចរលេខ ៥១ សរ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៨៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី និង សារាចរណែនាំ លេខ ០៦១ កហវ សរ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៨៣ ស្ដីពីរបបចំណូលហិរញ្ញវត្ថុ និង របបដកប្រាក់ បង្កើតបេឡាសហគ្រាសរដ្ឋ របស់ក្រសួងហិរញ្ញវត្ថុ។

– ក្រសួងឧស្សាហកម្ម បានពិនិត្យ និង ឯកភាព ។

សំរេច

ប្រការ ១ : ត្រូវបានកែសំរួលកំរិតចំណូលរដ្ឋលើផលរបរ របស់សហគ្រាសយន្តសាស្ត្រទី ៥ . ៦ . ៧ ដែលបានកំណត់ជាបណ្ដោះអាសន្ន ក្នុងសេចក្ដីសំរេចលេខ ១៩៦៧ កហវ ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៨៤ និងកំណត់ជាថ្មី អោយសហគ្រាសយន្តសាស្ត្រនីមួយ ៗ ក្រោមឱវាទក្រសួងឧស្សាហកម្មនូវសមាមាត្រ ដូចមានចែងក្នុងប្រការ ២ នៃ សេចក្ដីសំរេចនេះ ។

ប្រការ ២ : ប្រគល់សមាមាត្រចំណូលរដ្ឋ លើផលរបរលក់ចេញអោយសហគ្រាសយន្តសាស្ត្រទី ១ . ២ . ៣ . ៤ . ៨ . ៩ តាមកំរិតខាងក្រោម ៖

ល.រ	ឈ្មោះ សហគ្រាស	សមាមាត្រកំរិតចំណូលរដ្ឋ	ផ្សេង ៗ
១	យន្តសាស្ត្រទី ១	២០%	លើផលរបរលក់ចេញ
២	យន្តសាស្ត្រទី ២	២៥%	—
៣	យន្តសាស្ត្រទី ៣	២០%	—
៤	យន្តសាស្ត្រទី ៤	២៥%	—
៥	យន្តសាស្ត្រទី ៥	៣០%	—
៦	យន្តសាស្ត្រទី ៦	៤០%	—
៧	យន្តសាស្ត្រទី ៧	៣០%	—
៨	យន្តសាស្ត្រទី ៨	៣%	—
៩	យន្តសាស្ត្រទី ៩	២៥%	—

ប្រការ ៣ ៖ គ្រប់សហគ្រាសយន្តសាស្ត្រ មានភារកិច្ចបង់ចំណូលរដ្ឋគ្រប់ចំនួន ចូលថវិការដ្ឋក្រោយពេលទូទាត់ ។

— ក្នុងដំណើរអនុវត្ត ប្រសិនបើមានបាតុភាពសេដ្ឋកិច្ចកើតឡើងដោយថែដន្យសហគ្រាស ត្រូវរាយការណ៍ជាបន្ទាន់ជូន ក្រសួងហិរញ្ញវត្ថុ ដើម្បីធ្វើការកែតម្រូវបានទាន់ពេលវេលា ។

— មឹកប្រាក់លំអៀងសល់ ពីប្រាក់ចំណេញកំរិតកំណត់ និង ចំណូលរដ្ឋ សហគ្រាស មានភារកិច្ចបង់ចូលថវិការដ្ឋ ក្រោមរូបភាពជាខ្ទង់វិសមភាពថ្លៃ ។

ប្រការ ៤ : សេចក្ដីសំរេចនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៨៧ តទៅ ។

ភ្នំពេញ, ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៨៧

ជ. រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

អនុរដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ម៉ុន សម

សហគ្រាសសម្ព័ន្ធរោងពុម្ពទី ២
បោះពុម្ពនៅរោងពុម្ពសុខាភិបាល
លើកទី ១ ចំនួន ៥.០០០ ច្បាប់